# របាយការណ៍ស្ដីពី

## សិក្ខាសាលាផ្សព្វផ្សាយស្ដីពីលទ្ធផលនៃអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាឆ្នាំ ២០១៥ នៅប្រទេសកម្ពុជា

ទីកន្លែង៖ ភោជនីយដ្ឋានទន្លេបាសាក់ ២

ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០១៥ ម៉ោង ៨:០០ ព្រឹក ដល់ ម៉ោង ១២:០០ ថ្ងៃត្រង់




គណៈកម្មការរៀបចំ៖

The NGO Forum on Cambodia

Transparency International Cambodia

Save the Children

Cambodians for Resource Revenue Transparency

OXFAM

API Building Capacity for Change

DPA

GADC

ឧបត្ថម្ភដោយ៖

OXFAM

unicef

# មាតិកា

**១. សេចក្តីផ្តើម និងគោលបំណងនៃសិក្ខាសាលាផ្សព្វផ្សាយ**..........១

**២. សន្ទរកថាស្វាគមន៍ និងបើក**..........២

**៣. កម្មវិធី ១៖ លទ្ធផលនៃអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាឆ្នាំ ២០១៥ នៅប្រទេសកម្ពុជា**..........៤

៣.១ បទបង្ហាញលទ្ធផលនៃអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាឆ្នាំ២០១៥ នៅកម្ពុជា..........៥

៣.២ យោបល់គ្រលប់ពីវាគ្មិនកិត្តិយស..........៧

**៤. កម្មវិធី ២៖ ការពិភាក្សាលើផ្លូវឆ្ពោះទៅមុខក្នុងការកែលម្អ តម្លាភាពថវិកានៅក្នុងប្រទេសកម្ពុជា**..........១១

៤.១ បទបង្ហាញស្តីពី កំណែទំរង់ហិរញ្ញវត្ថុដំណាក់កាលទី៣៖ តម្លាភាពថវិកា និងការចូលរួមរបស់ប្រជាជន..........១១

៤.២ ការពិភាក្សាអំពីដំណើរការ ផ្លូវឆ្ពោះទៅរកការធ្វើឲ្យប្រសើរឡើងនូវតម្លាភាពថវិកានៅក្នុងប្រទេសកម្ពុជា..........១២

**៥. សន្ទរកថាបិទកម្មវិធី**..........១៥

**៦ .សេចក្តីសង្ខេបពីរបាយការណ៍សារពត៏មានសម្រាប់សិក្ខាសិលា ផ្សព្វផ្សាយស្តីពីលទ្ធផលនៃការអង្កេតលើការផ្សព្វផ្សាយព័ត៏មាន ថវិកា ឆ្នាំ ២០១៥**..........១៦

**៧. ឧបសម្ព័ន្ធ**

ឧបសម្ព័ន្ធទី ១៖ របៀបវារៈនៃសិក្ខាសិលាផ្សព្វផ្សាយលទ្ធផលនៃការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាឆ្នាំ ២០១៥..........១៣

ឧបសម្ព័ន្ធទី ២៖ បញ្ជីឈ្មោះអ្នកចូលរួម..........១៦

ឧបសម្ព័ន្ធទី ៣៖ ឯកសារធ្វើបទបង្ហាញរបស់ការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាឆ្នាំ ២០១៥..........២០

ឧបសម្ព័ន្ធទី ៤៖ ឯកសារធ្វើបទបង្ហាញស្តីពីផែនការសកម្មភាពដំណាក់កាលទី ៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ..........៣២

ឧបសម្ព័ន្ធទី ៥៖ របាយការណ៍សិក្ខាសិលាផ្សព្វផ្សាយលទ្ធផលនៃការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាឆ្នាំ ២០១៥..........៣៨

# របាយការណ៍ស្តីពី

# សិក្ខាសាលាផ្សព្វផ្សាយស្តីពីលទ្ធផលនៃ

# ការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាឆ្នាំ២០១៥ នៅប្រទេសកម្ពុជា

## ១. សេចក្តីផ្តើម និងគោលបំណងនៃសិក្ខាសាលាផ្សព្វផ្សាយ

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGO Forum) បាននឹងកំពុងសម្របសម្រួលការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា (Open Budget Survey-OBS) តាំងពីឆ្នាំ ២០០៨ ដើម្បីធ្វើការតស៊ូមតិក្នុងការបង្កើនតម្លាភាព និងភាពជឿជាក់ថវិកានៅកម្ពុជា។ កំរិតនៃតម្លាភាពថវិកានៅកម្ពុជា ត្រូវបានវាយតម្លៃឲ្យទទួលបាន ១៥ ពិន្ទុក្នុងចំណោម១០០ ពិន្ទុក្នុងឆ្នាំ ២០១០ និង ២០១២ ហើយ៧ ពិន្ទុ បានធ្លាក់ចុះក្នុងឆ្នាំ ២០១៥ ។ ការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា លើកនេះ គឺជាលើកទីបួនហើយ សម្រាប់ប្រទេសកម្ពុជា។ ការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាឆ្នាំ២០១៥ គឺមានលក្ខណៈដូចគ្នាទៅនឹង ការអង្កេតថវិកាឆ្នាំមុនៗដែរ ដោយថា ការអង្កេតនេះ វាយតម្លៃលើសសរស្តម្ភបីនៃតម្លាភាព និងគណនេយ្យភាព៖ (១) ការអង្កេតនេះ ពិចារណាទៅលើកំរិតដែលរដ្ឋាភិបាលថ្នាក់ជាតិផ្តល់ឲ្យសាធារណៈជនទាន់ពេលវេលា និង គ្រប់ជ្រុងជ្រោយនូវការទទួលបានឯកសារថវិកាចំនួន ៨ ដែលតម្រូវដោយការអនុវត្តន៍ល្អ (២) កំរិតនៃឱកាសផ្សេងៗសម្រាប់ការចូលរួមរបស់សាធារណៈជននៅក្នុងដំណើរការថវិកា និង (៣) ត្រួតពិនិត្យទៅលើសមត្ថភាពរបស់ស្ថាប័ននីតិបញ្ញត្តិ និង ស្ថាប័នសវនកម្មក្នុងការអនុវត្តន៍នូវតួនាទីត្រួតពិនិត្យតាមដានឲ្យមានប្រសិទ្ធិភាពទៅលើការគ្រប់គ្រងថវិការបស់រដ្ឋាភិបាល។

ចំណែកឯ គោលបំណងចំបងនៃសិក្ខាសាលាផ្សព្វផ្សាយចំពោះការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា ២០១៥ រួមមាន៖ (១) បង្ហាញពីគំហើញនៃការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា ២០១៥ សម្រាប់កម្ពុជា និង (២) បង្កើតជាវេទិកាសន្ទនាពិភាក្សាលើតម្លាភាពថវិកា និងគណនេយ្យភាព ក៏ដូចជា ស្វែងរកនូវដំណោះស្រាយល្អៗដើម្បីបង្កើនតម្លាភាព និងគណនេយ្យភាពនៅក្នុងប្រទេសកម្ពុជា។

# ២. សន្ទរកថាស្វាគមន៍ និងបើក

## ២.១ សន្ទរកថាស្វាគមន៍

នៅក្នុងសន្ទរកថាស្វាគមន៍ លោកបណ្ឌិត តឹក វណ្ណារ៉ា នាយកប្រតិបត្តិនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGO Forum) និងតាងនាមឲ្យគណៈកម្មការរៀបចំនៃសិក្ខាសាលាផ្សព្វផ្សាយនេះ[1] បានថ្លែងអំណរគុណដល់អ្នកចូលរួម និងវាគ្មិនកិត្តិយសដែលបានចូលរួមនៅក្នុងសិក្ខាសាលាផ្សព្វផ្សាយស្តីពីការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាឆ្នាំ២០១៥ នាថ្ងៃនេះ។ បន្ទាប់មក លោក វណ្ណារ៉ា បានលើកឡើងថា ថវិកាជាតិ គឺជាថវិការបស់ប្រជាពលរដ្ឋកម្ពុជាទាំងអស់គ្នា ដែលបានមកពីការខិតខំប្រឹងប្រែងបំពេញកាតព្វកិច្ចបង់ពន្ធ និងកម្រៃសេវាផ្សេងៗរបស់ពួកគាត់ នាពេលបច្ចុប្បន្នក៏ដូចជាក្នុងពេលអនាគតសម្រាប់ជាចំណូលរដ្ឋ និងទូទាត់បំណុលទាំងឡាយ ដែលរាជរដ្ឋាភិបាលបានខ្ចីក្នុងនាមពលរដ្ឋកម្ពុជា។ ភាពជាម្ចាស់នេះមានន័យថា ប្រជាជនគ្រប់រូប មានសិទ្ធិក្នុងការយល់ និងដឹងឮពីរបៀបដែលប្រាក់កាសរបស់ខ្លួនត្រូវបានប្រមូល និង ប្រើប្រាស់ដោយ របៀបណា។ ក្នុងន័យនេះ រាជរដ្ឋាភិបាលដែលជាអ្នកគ្រប់គ្រងថវិកា និងផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ មានកាតព្វកិច្ចក្នុងការរាយការណ៍ជូនប្រជាពលរដ្ឋវិញនូវព័ត៌មានទាំងនេះ។

លោក វណ្ណារ៉ា បានសង្កត់ធ្ងន់ថា តម្លាភាពថវិកាមានសារៈសំខាន់ក្នុងការរួមចំណែកជាមួយ រដ្ឋាភិបាលប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ តាមរយៈការចូលរួមរបស់សាធារណជន ក៏ដូចជាអង្គការសង្គមស៊ីវិលក្នុងការបំពេញបន្ថែមលើការតាមដាន និងត្រួតពិនិត្យការគ្រប់គ្រងថវិកាជាតិ ដើម្បីជួយកាត់បន្ថយ ក៏ដូចជាបញ្ចៀសការបាត់បង់ធនធានជាតិ។ ហេតុដូចនេះ ធនធានទាំងនេះ អាចវិនិយោគឲ្យមានប្រសិទ្ធិភាពក្នុង វិស័យអាទិភាពនានា ដូចជា វិស័យសុខាភិបាល អប់រំ កសិកម្ម អភិវឌ្ឍន៍ជនបទជាដើម។ លោក វណ្ណារ៉ា ក៏បានបន្តលើកឡើងថា ដើម្បីធានាឲ្យបានថា ថវិកាជាតិត្រូវបានប្រើប្រាស់សម្រាប់បំពេញសេចក្តីត្រូវការជាអាទិភាពនាពេលបច្ចុប្បន្ននិង វិនិយោគឲ្យចំគោលដៅសម្រាប់អនាគតរបស់ក្មេងជំនាន់ក្រោយ ប្រកបដោយប្រសិទ្ធិភាព សមធម៌ និងមិនមានផលប៉ះពាល់អវិជ្ជមានដល់ជីវិតរបស់ពលរដ្ឋក្រីក្រ បរិស្ថាន និងសង្គមជាតិទាំងមូល រាល់ការសម្រេចចិត្តនានាទាក់ទងនឹងថវិកាជាតិ ចាំបាច់ត្រូវមានតម្លាភាព គណនេយ្យភាព និងការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់។

ជាចុងក្រោយ លោក វណ្ណារ៉ា បានរាយការណ៍ថា ការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា (Open Budget Survey-OBS) បានដាក់ពិន្ទុឲ្យកម្ពុជា ទទួលបាន ៨ ពិន្ទុ ក្នុងចំណោម ១០០ ពិន្ទុ។ ដោយសារទទួលបាននូវពិន្ទុកម្រិតទាបនេះសម្រាប់កម្ពុជា លោក វណ្ណារ៉ា បានផ្តល់អនុសាសន៍មួយចំនួន ដើម្បីបង្កើនតម្លាភាពថវិកានាថ្ងៃអនាគត រួមមាន៖ (១) ការពង្រឹងតម្លាភាពថវិកា តាមរយៈផ្សព្វផ្សាយសេចក្តី ព្រាងច្បាប់ថវិកា ប្រចាំឆ្នាំ

[1] គណៈកម្មាធិការរៀបចំសិក្ខាសិលាផ្សព្វផ្សាយ រួមមាន API, CRRT, NGO Forum, OXFAM, Save the Children, GADC, DPA និង TIC ។

របស់រាជរដ្ឋាភិបាល ផ្សព្វផ្សាយរបាយការណ៍ត្រួតពិនិត្យពាក់កណ្តាលឆ្នាំ ព្រមទាំងផ្សព្វផ្សាយរបាយការណ៍ស្តីពីថវិកាសម្រាប់ប្រជាពលរដ្ឋ និងរបាយការណ៍ប្រចាំឆ្នាំឲ្យសមស្របទៅតាមពេលវេលា (២) ការពង្រឹងការចូលរួមរបស់សាធារណៈជនក្នុងដំណើរការថវិកា និង (៣)ការពង្រឹងលើការត្រួតពិនិត្យតាមរយៈ៖ (ក) បង្កើតការិយាល័យស្រាវជ្រាវថវិកាដែលមានលក្ខណៈឯកទេសសម្រាប់ស្ថាប័ននីតិបញ្ញត្តិ (ខ) ទាំងក្នុងច្បាប់ និងការអនុវត្តន៍ ត្រូវធានាថាស្ថាប័ននីតិបញ្ញត្តិ បានធ្វើការពិគ្រោះមុនពេលចំណាយថវិកា ដែលមិនបានព្រាងនៅក្នុងថវិកាដែលបានអនុម័ត និង (គ) ធានាថាស្ថាប័នត្រួតពិនិត្យមានថវិកាផ្គត់ផ្គង់គ្រប់គ្រាន់ក្នុងការបំពេញភារកិច្ចដែលត្រូវបានកំណត់ដោយស្ថាប័នឯករាជ្យ។

## ២.២ សន្ទរកថាគន្លឹះ

លោក ហ្សាវារ ខាស្ទីយូ អាល់វ៉ារេស្ស ប្រតិភូនៃសហភាពអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា បានថ្លែងនូវសន្ទរកថាគន្លឹះ ដោយបានគូសបញ្ជាក់ថា តម្លាភាព គឺមានសារៈសំខាន់ណាស់ សម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Public Financial Management Reform Program-PFMRP)។ លោក ហ្សាវារ បានលើកឡើងពីស្ថានភាពទូទៅរបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលរួមមានបួនជំហាន៖ (១) ថវិកាកាន់តែអាចជឿទុកចិត្តបាន ដោយអ្នកគ្រប់គ្រងថវិកា ទទួលបានធនធានដែលអាចព្យាករណ៍ និងជឿជាក់បាន (២) ការកែលម្អជាបឋមផ្នែកត្រួតពិនិត្យផ្ទៃក្នុង និងធ្វើឲ្យអ្នកគ្រប់គ្រងថវិកាមានគណនេយ្យភាព និង (៣) កែលម្អការផ្សារភ្ជាប់រវាងអាទិភាព សេដ្ឋកិច្ច គោលនយោបាយ និងគោលដៅសេវាទៅនឹងការធ្វើផែនការ និងការអនុវត្តន៍ថវិកា និង (៤) សមាហរណកម្មគណនេយ្យភាព និងការពិនិត្យឡើងវិញ ទាំងផ្នែកហិរញ្ញវត្ថុ និងសមិទ្ធិកម្ម។ លោក ហ្សាវារ បានសង្កត់ធ្ងន់ថា តម្លាភាពមិនត្រឹមតែចូលរួមចំណែកក្នុងការបង្កើនគណនេយ្យភាព ប៉ុន្តែ ថែមទាំងជួយសម្របសម្រួលការវិនិយោគបរទេស ព្រោះថាវិស័យឯកជន មានឆន្ទៈក្នុងការវិនិយោគ និងធ្វើអាជីវកម្មជាមួយរដ្ឋាភិបាលដែលមានតម្លាភាព។ លើសពីនេះទៀត ទាំងក្រុមហ៊ុនក្នុងស្រុក និងក្រុមហ៊ុនអន្តរជាតិ មានឆន្ទៈកាន់តែខ្លាំងក្នុងការចូលរួមនៅក្នុងដំណើរការលទ្ធកម្មសាធារណៈ ដែលមានតម្លាភាព ដោយផ្សព្វផ្សាយអំពីការប្រកួតប្រជែង និងតម្លៃរបស់លុយ/ថវិកា ហេតុដូចនេះ បង្កើន សេវាកម្មសាធារណៈសម្រាប់ប្រជាពលរដ្ឋ។

លោក ហ្សាវារ បានលើកឡើងថា វាមានសារៈសំខាន់ណាស់សម្រាប់រដ្ឋាភិបាល ក្នុងការផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋពីអ្វីដែលរដ្ឋាភិបាលកំពុងធ្វើ បើមិនអញ្ចឹងទេ ប្រជាពលរដ្ឋនឹងមិនដឹងពីវឌ្ឍនភាព ឬក៏សមិទ្ធិផលដែលរដ្ឋាភិបាលសម្រេចបានឡើយ។ ឧទាហរណ៍ ការវាយតម្លៃលើគណនេយ្យភាពហិរញ្ញវត្ថុ និងការចំណាយសាធារណៈ (Public Expenditure and Financial Accountability- PEFA) បង្ហាញថា បច្ចុប្បន្នរាជរដ្ឋាភិបាលកម្ពុជា អាចផលិតបាន តារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ (Tableau d'Opération Financière de l'Etat – TOFE- or Table of Public Financial Operation) ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងអាចផលិតរបាយ

ការណ៍ក្នុងរយៈពេល ២ សប្តាហ៍ បន្ទាប់ពីអំឡុងពេលធ្វើរបាយការណ៍។ ទោះបីជាយ៉ាងណាក៏ដោយ លោក ហ្សាវ៉ារ បានរៀបរាប់ថា វាគួរឲ្យឆ្ងល់ដែរថា ការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាឆ្នាំ២០១៥ បានបង្ហាញថា របាយការណ៍នៃតារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ មិនបានបោះផ្សាយឲ្យទាន់ពេលវេលា។ ហេតុដូចនេះ វាគួរឲ្យឆ្ងល់ដែលថា រដ្ឋាភិបាលអាចផលិតរបាយការណ៍នេះក្នុងរយៈពេល ២ សប្តាហ៍បន្ទាប់ពីអំឡុងពេលធ្វើរបាយការណ៍ ប៉ុន្តែមិនបានបោះផ្សាយជាសាធារណៈលើសពី បីខែ បន្ទាប់ពីអំឡុងពេលធ្វើរបាយការណ៍បញ្ចប់ ។ ដូចនេះហើយ ចំនុចនេះ អាចនឹងយកមកពិភាក្សានៅក្នុងវេទិកាថ្ងៃនេះ នៅពេលក្រោយ។

ជាចុងក្រោយ លោក ហ្សាវ៉ារ បានរៀបរាប់ថា តម្លាភាពថវិកា ត្រូវតែពង្រឹងបន្ថែមទៀត ធ្វើដូចនេះសាធារណៈជននឹងយល់ដឹងអំពីអ្វីដែលរដ្ឋាភិបាលបាននឹងកំពុងតែអនុវត្តចំពោះថវិកាសាធារណៈ។ លើសពីនេះទៀត លោក ហ្សាវ៉ារ បានអះអាងថា តម្លាភាព មិនមែនត្រឹមតែការការចេញផ្សាយ ឬការបោះពុម្ព ផ្សាយឯកសារ ឬរបាយការណ៍ថវិកានោះទេ ប៉ុន្តែថែមទាំងត្រូវពិចារណាលើ ការជឿជាក់ហិរញ្ញវត្ថុ និង គណនេយ្យភាពរបស់ស្ថាប័នរដ្ឋាភិបាលជាទូទៅ។ ដូចនេះ កត្តាទាំងនេះគប្បីត្រូវបានយកទៅពិចារណា នៅក្នុង ការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា។ ដោយសារតែ របកគំហើញនៃការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកានេះធ្វើឡើងនៅក្នុងឆ្នាំ២០១៤ លោក ហ្សាវ៉ារ ក៏មានបំណងពិភាក្សាលើវឌ្ឍនភាពដែលសម្រេចបាន លើកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចាប់តាំងពីចុងឆ្នាំ ២០១៤ ព្រោះថា ក្នុងរយៈពេលនេះ លោកសង្កេតឃើញថា មានវឌ្ឍនភាពលើការគ្រប់គ្រងថវិកាផងដែរ។ លោក ហ្សាវ៉ារ ក៏បានលើកឡើងថា វាមានសារៈសំខាន់ ក្នុងការពិនិត្យមើល អនាគតទៅមុខ និងប្រើប្រាស់ការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាឆ្នាំ ២០១៥ ជាមូលដ្ឋាន ក្នុងកែលម្អតម្លាភាពថវិកាក្នុងរយៈពេលខ្លី និងរយៈពេលវែង ។ ជាចុងក្រោយលោក ហ្សាវ៉ារ បានសាទរក្រុមការងារថវិការបស់អង្គការមិនមែនរដ្ឋាភិបាល ដែលបានផ្តួចផ្តើមរៀបចំវេទិកាកិច្ចសន្ទនានេះ ព្រមទាំងធ្វើការរួមគ្នាដើម្បីបង្កើនតម្លាភាព និងគណនេយ្យភាពថវិកា។

# ៣. កម្មវិធី ១៖ លទ្ធផលនៃអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាឆ្នាំ ២០១៥ នៅប្រទេសកម្ពុជា

វគ្គនេះ ត្រូវបានសម្របសម្រួលដោយ លោក ប៉ែន រក្សា អង្គការតម្លាភាពកម្ពុជា (TIC) ខណៈដែល លោក បណ្ឌិត តឹក វណ្ណារ៉ា គឺជាវាគ្មិន ដែលបង្ហាញពីលទ្ធផលនៃអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាឆ្នាំ២០១៥ នៅប្រទេសកម្ពុជា។ ទន្ទឹមនឹងនេះដែរ ឯកឧត្តម សុន ឆ័យ អនុប្រធានគណៈកម្មការទី២នៃរដ្ឋសភា លោក ឡាយ សុខឃៀង អនុប្រធាននាយកដ្ឋានថវិកានីយកម្ម លោក ហ្សាវ៉ារ ខាស្មីយូ អាល់វ៉ារេស្ស គឺអ្នកផ្តល់យោបល់ត្រលប់។

## ៣.១ បទបង្ហាញលទ្ធផលនៃអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាឆ្នាំ២០១៥ នៅកម្ពុជា

លោកបណ្ឌិត តឹក វណ្ណារ៉ា បានធ្វើបទបង្ហាញដោយផ្ដោតទៅលើចំនុចបីសំខាន់ៗ រួមមាន៖ (១) សេចក្ដីផ្ដើមនៃអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា និង វិធីសាស្ត្ររបស់ការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា (២) លទ្ធផលនៃការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកានៅថ្នាក់ពិភពលោក និងនៅកម្ពុជា និង (៣) អនុសាសន៍សំខាន់ៗ។

ជាបឋម លោកបណ្ឌិត វណ្ណារ៉ា បានលើកឡើងថា អង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា ២០១៥ ត្រួតពិនិត្យវាយតម្លៃលើទិដ្ឋភាព៣នៃរបៀបដែលរដ្ឋាភិបាលនៃប្រទេសមួយគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ទិដ្ឋភាពទាំង៣នោះរួមមាន៖ តម្លាភាពនៃថវិកា ការចូលរួមរបស់សាធារណៈជនក្នុងដំណើរការថវិកា និងការត្រួតពិនិត្យថវិកា។ លោក វណ្ណារ៉ា ក៏បានសង្ខេបជូនអ្នកចូលរួមអំពី វិធីសាស្ត្ររបស់ការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាដែលរួមមានប្រាំដំណាក់ជាប់ៗគ្នា រួមមាន៖ (១) អ្នកជំនាញប្រចាំប្រទេសនីមួយៗបំពេញកម្រងសំនួរ (២) អង្គការភាពជាដៃគូរថវិកាអន្តរជាតិ (IBP) ធ្វើការត្រួតពិនិត្យការអង្កេត (៣) អ្នកឯករាជ្យខាងក្រៅធ្វើការត្រួតពិនិត្យការអង្កេត (៤) រាជរដ្ឋាភិបាល ធ្វើការត្រួតពិនិត្យ និង (៥) អង្គការភាពជាដៃគូរថវិកាអន្តរជាតិធ្វើការត្រួតពិនិត្យចុងក្រោយ។ ដំណើរការនៃអង្កេតនេះមានរយៈពេល ១៨ ខែ។ ការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិការួមមាន ១៤០ សំណួរ និង១០៩ សូចនករ ធ្វើការវាស់វែងតម្លាភាពថវិកា។ លើសពីនេះទៀត សូចនាករទាំងនេះ ត្រូវបានគេប្រើប្រាស់ដើម្បីវាស់វែងថាតើ រដ្ឋាភិបាលធ្វើការផលិត ឬចែកផ្សាយឯកសារថវិកាចំនួនប្រាំបីចំបងៗ[2] ជូនប្រជាពលរដ្ឋ ឲ្យទាន់ពេលវេលា និងថាតើ ទិន្នន័យនៅក្នុងឯកសារទាំងនេះ មានលក្ខណៈគ្រប់ជ្រុងជ្រោយ និងមានប្រយោជន៍ឬទេ។ លើសពីនេះទៅទៀត ១៦ សូចនាករធ្វើការវាស់វែងឱកាសសម្រាប់សាធារណៈចូលរួមក្នុងដំណើរការថវិកា និង ១៦ សូចនាករទៀត ធ្វើការវាស់វែងសម្រាប់វាយតម្លៃដោយ អង្គនីតិបញ្ញត្តិ និង សវនករលើការត្រួតពិនិត្យថវិកា (ព័ត៌មានលម្អិត មើលឧបសម្ព័ន្ធ 3) ។

បន្ទាប់មក លោកបណ្ឌិត វណ្ណារ៉ា បានបង្ហាញពីរបកគំហើញនៃការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាដោយគូសបញ្ជាក់ថា ប្រជាជនមួយភាគធំលើពិភពលោករស់នៅក្នុងប្រទេសដែលផ្ដល់ជូនព័ត៌មានថវិកាតិចតួចៗ រវាងឆ្នាំ ២០១២ និងឆ្នាំ ២០១៥ តម្លាភាពថវិកាលើពិភពលោកមានការកើនឡើងតិចតួចៗ បញ្ហាទាក់ទងនឹងការខ្វះខាតនូវតម្លាភាព គឺចូលរួមចំណែកដោយការចូលរួមរបស់សាធារណៈជនក្នុងដំណើរការថវិកានៅមានកំរិតតិចតួច និងកង្វះខាតសមត្ថភាពលើការត្រួតពិនិត្យថវិកាជាផ្លូវការ។ លទ្ធផលនៃការអង្កេតបង្ហាញថា ពិន្ទុជាមធ្យមសម្រាប់ប្រទេស ដែលបានធ្វើការអង្កេត គឺ ៤៥ ក្នុងចំណោម ១០០ ពិន្ទុ។ ទន្ទឹមនឹងនេះដែរ

[2] ឯកសារថវិកាទាំង ៨ រួមមាន សេចក្តីព្រាងច្បាប់ថវិកាប្រចាំ (២) របាយការណ៍បុរេថវិកា (១)ឆ្នាំរបស់រាជរដ្ឋាភិបាល លថវិកាដែ (៣) បានអនុម័ត (៤)របាយការណ៍ថវិកាសម្រាប់ប្រជាពលរដ្ឋ របាយ (៧) របាយការណ៍ពាក់ កណ្តាលឆ្នាំ (៦) របាយការណ៍ក្នុងឆ្នាំ (៥) ការណ៍បំណាច់ឆ្នាំ របាយការណ៍សវនកម្ម (៨)

អង្គនិតិបញ្ញត្តិនៅក្នុង ៦៦ ប្រទេសប្រឈមមុខនឹងការខ្វះខាតសមត្ថភាពយ៉ាងធ្ងន់ធ្ងរដើម្បីត្រួតពិនិត្យថវិកា។ លើសពីនេះទៀត មួយភាគបីនៃ ១០២ ប្រទេស បង្ហាញថា អង្គនិតិបញ្ញត្តិមិនត្រូវបានផ្តល់ពេលវេលាគ្រប់គ្រាន់ដើម្បីត្រួតពិនិត្យសំណើសុំថវិកាមុនពេលអនុម័ត។

ពាក់ព័ន្ធនឹងរបកគំហើញនៃការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា សម្រាប់ប្រទេសកម្ពុជា លោកបណ្ឌិត វណ្ណារ៉ា បានរាយការណ៍ថា ខណៈដែលការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាលើកនេះ គឺត្រូវបានអនុវត្តលើកទីបួនហើយសម្រាប់កម្ពុជា[3]ចាប់តាំងពីឆ្នាំ ២០០៨ ។ លទ្ធផលនៃការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាឆ្នាំ២០១៥ ឆ្លុះបញ្ចាំងពីព័ត៌មានដែលប្រមូលបានក្នុងឆ្នាំ ២០១៤។ ប្រសិនបើ ប្រៀបធៀបទៅនឹងចំណាត់ថ្នាក់សកលលោក ប្រទេសកម្ពុជា ទទួលបានពិន្ទុ ៨ ក្នុង ១០០ពិន្ទុ។ ពិន្ទុនៃសន្ទស្សន៍បើកទូលាយថវិកា (OBI) ២០១៥សម្រាប់កម្ពុជា បានធ្លាក់ចុះចំនួន ៧ ពិន្ទុ ប្រសិនបើប្រៀបធៀបទៅនឹងពិន្ទុសន្ទស្សន៍នៃការផ្សព្វផ្សាយព័ត៌មានថវិកាឆ្នាំ២០១២ ដែលមានចំនួន ១៥ ពិន្ទុ។ ការណ៍ដែលប្រទេសកម្ពុជា ទទួលបាន ពិន្ទុ ៨ ក្នុង ១០០ ពិន្ទុ បង្ហាញថា ការផ្តល់ឱកាសសម្រាប់សាធារណៈជនដើម្បីចូលរួមក្នុងដំណើរការថវិកា គឺមានលក្ខណៈនៅមានកំរិតនៅឡើយ។ ការទទួលបានពិន្ទុនេះ ក៏មានន័យថា រាជរដ្ឋាភិបាល ផ្តល់ជូនសាធារណៈជន នូវព័ត៌មានតិចតួច ស្តីពីថវិការបស់រដ្ឋាភិបាលថ្នាក់ជាតិ និងសកម្មភាពហិរញ្ញវត្ថុនានា។ ការណ៍នេះ បង្កឲ្យប្រជាពលរដ្ឋមានភាពលំបាកក្នុងការទាមទារឲ្យរដ្ឋាភិបាលទទួលខុសត្រូវចំពោះ ការគ្រប់គ្រងនូវថវិកាសាធារ-ណៈ ដែលរួមមាន ការប្រមូលចំណូល និងមូនិធិសាធារណៈ។ លើសពីនេះទៀត លោកបណ្ឌិត វណ្ណារ៉ា បានគូសបញ្ជាក់ថា អង្គនិតិបញ្ញត្តិ និងស្ថាប័នសវនកម្មជាន់ខ្ពស់ធ្វើការត្រួតពិនិត្យតាមដានថវិកា នៅមានកំរិតនៅឡើយ។

គួរឲ្យកត់សម្គាល់ផងដែរថា ពិន្ទុដែលកម្ពុជាទទួលបាន គឺស្ថិតនៅលំដាប់ថ្នាក់ទាបបំផុតទី២ បន្ទាប់ពី ប្រទេសមីយ៉ាន់ម៉ា ដែលទទួលបាន ២ ពិន្ទុ។ ក្នុងចំណោមរដ្ឋដែលជាសមាជិកអាស៊ាន ប្រទេសហ្វីលីពីន ទទួលបានពិន្ទុខ្ពស់ជាងគេ (៦៤ ពិន្ទុ) បន្ទាប់មក គឺ ឥណ្ឌូនេស៊ី (៥៩ ពិន្ទុ) និង ប្រទេស ម៉ាឡេស៊ី (៤៦)។ ជាចុងក្រោយ លោកបណ្ឌិត វណ្ណារ៉ា បានផ្តល់ជូននូវអនុសាសន៍មួយចំនួនសម្រាប់កែលំអតម្លាភាពថវិកា ការចូលរួមរបស់សាធារណៈជននៅក្នុងដំណើរការថវិកា និងការត្រួតពិនិត្យតាមដានថវិកា ពីសំណាក់ស្ថាប័ននីតិបញ្ញត្តិ និងស្ថាប័នសវនកម្ម។ *សូមពិនិត្យមើលព័ត៌មានលំអិតបន្ថែមទៀត ក្នុងឯកសារបទបង្ហាញរបស់ លោកបណ្ឌិត តឹក វណ្ណារ៉ា នៅក្នុង ឧបសម្ព័ន្ធទី ២។*

[3] ការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា គឺត្រូវបានអនុវត្តដោយ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា

## ៣.២ យោបល់ត្រលប់ពីវាគ្មិនកិត្តិយស

បន្ទាប់ពីការធ្វើបទបង្ហាញរបស់ លោកបណ្ឌិត វណ្ណារ៉ា ស្តីពីរបកគំហើញនៃការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា អ្នកផ្តល់យោបល់ ឬវាគ្មិនកិត្តិយសបានផ្តល់យោបល់ត្រលប់ទៅលើ របកគំហើញនៃការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា និងការបើកទូលាយនៃថវិកាជាតិកម្ពុជា នាប៉ុន្មានឆ្នាំចុងក្រោយនេះ។ ជាបឋម ឯកឧត្តម សុន ឆ័យ បានលើកឡើងថា ព័ត៌មានថវិកា ហាក់បី ដូចជា មិនមានការបើកទូលាយ។ ឯកឧត្តម បានបញ្ជាក់ថា មតិយោបល់របស់ឯកឧត្តម ស្រដៀងគ្នាទៅនឹងអ្វី ដែលអង្គការមិនមែនរដ្ឋាភិបាលបានរកឃើញកន្លងមក។ ថ្មីៗនេះ បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាត្រូវគេយកមក ពិភាក្សា និងកែសម្រួលឡើងវិញ ដើម្បីធ្វើឲ្យព័ត៌មានថវិកាកាន់តែមានភាពបើកចំហ។ ឯកឧត្តម សុន ឆ័យ ក៏បានលើកឡើងផងដែរថា នៅពេលអនាគត អង្គការសង្គមស៊ីវិលនឹងត្រូវអនុញ្ញាត្តិឲ្យចូលជួបគណៈ កម្មាធិការ២នៃរដ្ឋសភា ដើម្បីពិភាក្សាលើឯកសារថវិកាដែលពាក់ព័ន្ធទាំងឡាយ។ ទាក់ទងនឹងការរៀបចំ សំណើថវិកា ឯកឧត្តមបានសង្កត់ធ្ងន់ថា និតិវិធីនៃការបង្កើតសំណើថវិកាត្រូវតែធ្វើឲ្យបានត្រឹមត្រូវ និងប្រើវិធីសាស្ត្រដោយមានការចូលរួមពីថ្នាក់មូលដ្ឋាន (ឧទាហរណ៍ ពីថ្នាក់ឃុំ ទៅថ្នាក់ស្រុក ទៅថ្នាក់ខេត្ត និង ទៅថ្នាក់ជាតិ)។

ក្រៅពីនេះ ឯកឧត្តម សុន ឆ័យ បានលើកឡើងថា ការធ្វើសវនកម្មលើថវិកាពីសំណាក់អាជ្ញាធរសវនកម្មជាតិ (NAA) គប្បីធ្វើឡើងដោយឯករាជ្យ។ ឯកឧត្តម ក៏បានគូសបញ្ជាក់ផងដែរថា ការធ្វើសវនកម្មលើការចំណាយលើប្រាក់បៀវត្សរ៍លើបុគ្គលិកមួយចំនួន ឬ "បុគ្គលិកខ្មោច" នៅក្រសួងការពារជាតិគប្បីធ្វើអនុវត្ត។ ទន្ទឹមនេះនឹងគេសង្កេតឃើញថា មន្ត្រីរាជការស៊ីវិល មិនមានការប្តេជ្ញាចិត្តពេញលេញក្នុងការធ្វើការនៅស្ថាប័នសាធារណៈ (ឧទាហរណ៍៖ មកធ្វើការយឺត និងចេញពីធ្វើការលឿន)។ ឯកឧត្តម ក៏បានបន្តលើកឡើងថា អាជ្ញាធរសវនកម្មជាតិ ហាក់ដូចជាមិនហ៊ានធ្វើសវនកម្មចំពោះកិច្ចការទាំងនេះទៅលើស្ថាប័នសាធារណៈនានា ដែលរួមមាន រដ្ឋសភា តុលាការកំពូល ជាដើម។

ទោះបីជាយ៉ាងនេះក្តី ជាចុងក្រោយ ឯកឧត្តម សុន ឆ័យ បានកោតសរសើរថា រាជរដ្ឋាភិបាល ជាពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានការប្តេជ្ញាចិត្តជាងមុន។ ឧទាហរណ៍ ការគ្រប់គ្រងការប្រមូលចំណូលមានការប្រសើរ ហេតុដូចនេះ ការគ្រប់គ្រងការចំណាយថវិកា គប្បីកែលម្អ និងពង្រឹងផងដែរ។

បន្ទាប់ពី ឯកឧត្តម សុន ឆ័យ បានផ្តល់មតិយោបល់ លោក សុខឃៀង នាយករងនាយកដ្ឋានថវិកាតំណាងមកពីក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានផ្តល់មតិយោបល់ដោយសង្ខេបទៅលើរបកគំហើញ នៃការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា ថា "គាត់មិនមានមតិយោបល់ច្រើនទេចំពោះលទ្ធផលនៃការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកានេះ ពីព្រោះថា គាត់ គឺអ្នកបំពេញកម្រងសំណួររបស់ការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា"។ ទោះបីជាយ៉ាងណាក៏ដោយ លោក សុខឃៀង បានលើកឡើងថា ពិន្ទុ (៨) ដែលកម្ពុជាទទួលបានពីការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា គឺមិនអាក្រក់ទេ ប្រសិនបើធ្វើការប្រៀប

ធៀបជាមួយប្រទេសចិន (៦) និងប្រទេសម៉ាឡេស៊ី (១២)។ លើសពីទៀត ថ្មីៗនេះ មានការធ្វើបច្ចុប្បន្នភាពលើការគ្រប់គ្រងថវិកា។ ឧទាហរណ៍ នៅក្នុងឆ្នាំ ២០១៥ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានកែលម្អការចែករំលែកព័ត៌មានថវិកាជាមួយភាគីដែលពាក់ព័ន្ធ ព្រោះថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំសិក្ខាសាលា ស្តីពីក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ដោយបានអញ្ជើញដៃគូអភិវឌ្ឍន៍អង្គការសង្គមស៊ីវិល ស្ថាប័នស្រាវជ្រាវ និងស្ថាប័នសិក្សាអប់រំ ដើម្បីផ្តល់ធាតុចូល និងមតិយោបល់នានាទៅលើក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនេះ ក៏ដូចជាធ្វើការឆ្លុះបញ្ចាំងពីតម្រូវការរបស់សាធារណៈជន និងអង្គការសង្គមស៊ីវិល ជាពិសេស។

លើសពីនេះទៀត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏បានរៀបចំសិក្ខាសាលាមួយផ្សេងទៀត ស្តីពីកំណើនរយៈពេលខ្លី និងរយៈពេលវែង ព្រមទាំងសំណើថវិកា ជាមួយស្ថាប័ន/ក្រសួងពាក់ព័ន្ធនានា (LMs/LAs)។ សិក្ខាសាលានេះ បានផ្តល់ឱកាសសម្រាប់ស្ថាប័ន/ក្រសួងពាក់ព័ន្ធនានា ដើម្បីពិភាក្សាពីសំណើថវិការបស់ពួកគាត់ជាមួយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ជារួម លោក សុខឃៀង បានលើកឡើងថាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បាននឹងកំពុងបន្តពង្រឹងការអនុវត្តន៍ដំណើរការនៃការរៀបចំសំណើថវិកាដែលមានស្រាប់ជាមួយស្ថាប័ន/ក្រសួង ពាក់ព័ន្ធនានា ។

បន្ទាប់ពីនេះ លោក ហ្សាវ៉ារ មកពីសហគមន៍អឺរ៉ុប បានផ្តល់មតិយោបល់ទៅលើ របកគំហើញរបស់ការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា ថា ទោះបីជា លទ្ធផលរបស់ការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា និងឯកឧត្តម សុន ឆ័យបានបង្ហាញថា តម្លាភាពថវិកា នៅមានកម្រិតក៏ដោយក៏លោកបានសង្កេតឃើញភាពវិជ្ជមានដែលថា ព័ត៌មាន និង ការគ្រប់គ្រងថវិកាត្រូវបានកែលម្អជាបណ្តើរៗ ទោះបីជាមិនមានលក្ខណៈធំទូលាយ ក៏ដោយ។ លោក ហ្សាវ៉ារ បានបន្តលើកឡើងថា វាមានសារៈសំខាន់ណាស់ក្នុងការពិនិត្យមើលការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា ដើម្បីពិចារណាថាតើ ស្ថានភាពនៃព័ត៌មានថវិកាកាន់តែប្រសើរ ឬក៏កាន់តែអាក្រក់។ នៅក្នុងន័យនេះ វាគួរឲ្យកត់សម្គាល់ដែលត្រូវពិនិត្យមើលរបាយការណ៍ចុងឆ្នាំ (year-end-report) ដែលជារបាយការណ៍មួយក្នុងចំណោមរបាយការណ៍ទាំង៨ ដែលវាយតម្លៃដោយការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា។ ការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា លើកមុន បានចាត់ទុកថា តារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ គឺ របាយការណ៍ចុងឆ្នាំ ប៉ុន្តែ ការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា បច្ចុប្បន្ន មិនបានចាត់ទុកថា តារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ ជារបាយការណ៍ចុងឆ្នាំឡើយ។ ហេតុដូចនេះ លោក ហ្សាវ៉ារ បានស្នើថា វាមានសារៈសំខាន់ណាស់ ក្នុងការបកស្រាយការប្រែប្រួលបែបនេះនៅក្នុងបទបង្ហាញ ក៏ដូចជានៅក្នុង របាយការណ៍ ព្រោះថា ការផ្លាស់ប្តូរនេះ អាចនាំឲ្យមានការធ្លាក់ចុះពិន្ទុដែលកម្ពុជាទទួលបានក្នុងការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា ទៅលើតម្លាភាពថវិការបស់កម្ពុជា។ ធ្វើដូចនេះ វានឹងមិនធ្វើឲ្យស្ថានភាពបច្ចុប្បន្ននៃការគ្រប់គ្រងព័ត៌មានថវិកាមានសភាពកាន់តែអាក្រក់នោះឡើយ។

ទោះបីជាយ៉ាងណាក៏ដោយ ជាចុងក្រោយ លោក ហ្សាវារ បានបន្ថែមទៀតថា ប្រសិនបើយើងពិចារណា លើរបកគំហើញរបស់ការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា រដ្ឋាភិបាលគប្បីធ្វើការឲ្យកាន់តែជិតស្និទ្ធិជាមួយ រដ្ឋសភា និងអាជ្ញាធរសវនកម្មជាតិដើម្បីបង្កើនតម្លាភាពនិងគណនេយ្យភាពថវិកា (ឧទាហរណ៍៖ បោះពុម្ពផ្សាយ ឯកសារថវិកាដែល មានស្រាប់)។

## សំណួរ និងចម្លើយ

### សំណួរ៖

១) កញ្ញា លីដា មកពី World Vision Cambodia បានសួរអំពីវិធីសាស្ត្រ និងដំណើរការនៃការប្រមូលព័ត៌មាន ដូចខាងក្រោម៖

ក) ហេតុអ្វីការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា កំណត់លក្ខខណ្ឌ “មិនបានផលិត/បោះពុម្ពផ្សាយ យឺត [not produced/published late]” នៅក្នុងក្រុមតែមួយ?

ខ) ការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា ត្រូវបានធ្វើឡើងក្នុងឆ្នាំ២០១៤ ហេតុអ្វីលទ្ធផលនៃអង្កេត ទើបតែចេញនៅចុងឆ្នាំ២០១៥?

២) លោក គង់ សុភា មកពីកាសែត ឌឺខេមបូឌាដេលី៖ តើមានផលប៉ះពាល់អ្វីទៅលើសមតុល្យនៃថវិកាជាតិ ដែលអាចបណ្តាលមកពីរបកគំហើញរបស់ការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា ដែលកម្ពុជាទទួលបាន ពិន្ទុទាប?

៣) លោកស្រី រស់ រួន មកពីអង្គការ FACT៖ តើយើងគួរធ្វើយ៉ាងដូចម្តេចដើម្បីបង្កើនតម្លាភាពថវិកា? តើ មានផលប៉ះពាល់អ្វីខ្លះចំពោះការផ្តល់ថវិការបស់ម្ចាស់ជំនួយ ដែលអាចបណ្តាលមកពីរបកគំហើញ របស់ការ អង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា ដែលកម្ពុជាទទួលបានពិន្ទុទាប?

### ចម្លើយ ៖

លោកបណ្ឌិត វណ្ណារ៉ា នាយកប្រតិបត្តិនៃ អង្គការ NGO Forum បានឆ្លើយតបទៅនឹងសំណួរទី១ (ខ) ថា ការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា នេះ ត្រូវបានធ្វើឡើងក្នុងរយៈពេល១៨ ខែ ដែលពាក់ព័ន្ធនឹង ដំណាក់កាលបួនចំបងៗនៃការត្រួតពិនិត្យគុណភាព និងភាពគ្រប់ជ្រុងជ្រោយនៃរបកគំហើញរបស់ការអង្កេត លើការផ្សព្វផ្សាយព័ត៌មានថវិកា រួមមាន៖ (១) ត្រួតពិនិត្យលើ របកគំហើញបឋមនៃការអង្កេតលើការផ្សព្វផ្សាយ ព័ត៌មានថវិកា ដោយភាគីពាក់ព័ន្ធនានា (២) ត្រួតពិនិត្យលើរបកគំហើញនៃការអង្កេតលើការផ្សព្វផ្សាយ ព័ត៌មានថវិកា ដោយអង្គការភាពជាដៃគូនៃថវិកាអន្តរជាតិ (IBP) (៣) ត្រួតពិនិត្យលើរបកគំហើញនៃការអង្កេត

លើការផ្សព្វផ្សាយព័ត៌មានថវិកា ដោយអ្នកជំនាញការឯករាជ្យ និង (៤) ត្រួតពិនិត្យលើរបកគំហើញនៃការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា ដោយរាជរដ្ឋាភិបាល។

ពាក់ព័ន្ធនឹងការឆ្លើយតបទៅនឹងសំណួរដែលនៅសេសសល់ លោក សុខឃៀង តំណាងមកពីក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានឆ្លើយតបថារបាយការណ៍ តារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈឬ (ត្រូវគេចាត់ទុកថាជារបាយការណ៍ចុងឆ្នាំ) មានការយឺតយ៉ាវក្នុងការដាក់បញ្ចូលទៅក្នុងគេហទំព័ររបស់ក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយសារតែបញ្ហារដ្ឋបាល ដែលអាចបណ្តាលមកពីកង្វះការសម្របសម្រួលគ្នារវាងនាយកដ្ឋានពីរ (ឧទាហរណ៍៖ នាយកដ្ឋាន បច្ចេកវិទ្យា និងនាយកដ្ឋានស្ថិតិ)។ បញ្ហានេះ ត្រូវបានពន្យល់ទៅកាន់ម្ចាស់ជំនួយរួចរាល់ហើយ ជាពិសេស សហព័ន្ធអឺរ៉ុប អំពីភាពយឺតយ៉ាវនៃការចេញផ្សាយតារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈនៅលើវេបសាយរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ លោកសុខឃៀងបានបកស្រាយបន្តទៀតថា លទ្ធផលរបស់ ការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា មិនមានផលប៉ះពាល់អវិជ្ជមានទៅដល់ម្ចាស់ជំនួយថវិកាទេ ពីព្រោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀមរាប់ពីបញ្ហា ដែលកើតមានទៅកាន់ម្ចាស់ជំនួយ។ លោក សុខឃៀង បានអះអាងថា រដ្ឋាភិបាល ជាពិសេស ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានធ្វើឲ្យមានវឌ្ឍនភាពគួរឲ្យកត់សម្គាល់ទៅលើការគ្រប់គ្រងថវិកា ប៉ុន្តែ រដ្ឋាភិបាល មិនបានផលិតឯកសារជាច្រើន។ ដោយសារតែ និយមន័យថ្មីនៃរបាយការណ៍ចុងឆ្នាំ គ្របដណ្តប់លើ "ច្បាប់ទូទាត់ថវិកា" ហេតុដូចនេះ លោក សុខឃៀង សង្ឃឹមថា ពិន្ទុ ការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា សម្រាប់កម្ពុជាអាចកើនឡើងនៅឆ្នាំបន្ទាប់ទៀត។ ឧទាហរណ៍ ច្បាប់ទូទាត់ថវិកា ឆ្នាំ២០១៤ នឹងត្រូវរៀបចំឲ្យស្របជាមួយច្បាប់ថវិកាជាតិឆ្នាំ ២០១៦។ ហេតុដូចនេះ ការចេញផ្សាយនៃច្បាប់ទូទាត់ថវិកានាពេលខាងមុខ អាចចូលរួមចំណែកក្នុងការធ្វើឲ្យប្រសើរឡើងនូវពិន្ទុ ការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា សម្រាប់ឆ្នាំបន្ទាប់។ ជារួម លោក សុខឃៀង បានលើកឡើងថា ក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាពិសេស ឯកឧត្តមរដ្ឋមន្ត្រី មានការប្តេជ្ញាចិត្តក្នុងការធ្វើឲ្យប្រសើរឡើងនូវតម្លាភាព និងគណនេយ្យភាពថវិកា (ឧទាហរណ៍ ការរៀបចំសិក្ខាសាលា ស្តីពីក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ដើម្បីប្រមូលធាតុចូលពីភាគីដែលពាក់ព័ន្ធ)។

បន្ទាប់ពីការឆ្លើយតបពីសំណាក់តំណាងក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លោក លោក ហ្សាវារ ត្រូវបានផ្តល់ឱកាសក្នុងការផ្តល់មតិយោបល់បន្ថែមទៀតទៅលើរបកគំហើញនៃការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា និងការប្តេជ្ញាចិត្តរបស់គាត់ ក្នុងនាមជាតំណាងនៃសហគមន៍ម្ចាស់ជំនួយ ដើម្បីគៀងគរភាគីពាក់ព័ន្ធ ឲ្យធ្វើការរួមគ្នាក្នុងការបង្កើនតម្លាភាពថវិកា។ ជាបឋម លោក ហ្សាវារ គាំទ្រនូវអ្វីដែលលោក សុខឃៀងបានឆ្លើយតបចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការបង្កើនតម្លាភាពថវិកា។ បន្ទាប់មក លោក ហ្សាវារ ក៏បានបញ្ជាក់ថា "*យើងមិនគួរនៅក្នុងអន្ទាក់របស់តួលេខ ឬក៏ពិន្ទុឡើយ*"។ ទោះបីជា តួលេខ/ពិន្ទុបែបនេះ អាចបកស្រាយនូវស្ថានភាពនៃបរិបទជាក់លាក់មួយក៏ដោយ វាមានសារៈសំខាន់ណាស់ក្នុងការគិតគូរពិចារ-

ណាទៅលើវិធីសាស្ត្រនៃការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា។ លើសពីនេះទៀត លោក ហ្សាវ៉ារ ក៏បានគូសបញ្ជាក់ថា វាកាន់តែប្រសើរក្នុងការប្រមើលមើលទៅមុខ នៅក្នុងក្របខណ្ឌនៃការធ្វើឲ្យប្រសើរឡើង នៅក្នុងការផលិតរបាយការណ៍ថវិកាប្រកបដោយគុណភាព លទ្ធកម្ម និងប្រព័ន្ធទាំងមូល។

# ៤. កម្មវិធី ២៖ ការពិភាក្សាលើផ្លូវឆ្ពោះទៅមុខក្នុងការកែលម្អតម្លាភាពថវិកានៅក្នុងប្រទេសកម្ពុជា

វគ្គនេះ ត្រូវបានសម្របសម្រួលដោយ លោក ពុធ សុភ: មកពី អង្គការសង្គ្រោះកុមារ (Save the Children) ខណៈដែល លោក មាស សេនសាន អនុប្រធានអគ្គលេខាធិការដ្ឋានការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាវាគ្មិន ដែលបង្ហាញពីកំណែទំរង់ហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ ជាពិសេស ផ្តោតលើតម្លាភាពថវិកា និងការចូលរួមរបស់ប្រជាជន ។ ទន្ទឹមនឹងនេះដែរ លោក ហ្សាវ៉ារ ខាស្ទីយូ អាល់វ៉ារេស្ស និង លោកបណ្ឌិត តឹក វណ្ណារ៉ា គឺអ្នកផ្តល់យោបល់ត្រលប់។

## ៤.១ បទបង្ហាញស្តីពី កំណែទំរង់ហិរញ្ញវត្ថុដំណាក់កាលទី៣៖ តម្លាភាពថវិកា និងការចូលរួមរបស់ប្រជាជន

លោក មាស សេនសាន បានធ្វើបទបង្ហាញពីកំណែទំរង់ហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ ជាពិសេស ផ្តោតលើតម្លាភាពថវិកា និងការចូលរួមរបស់ប្រជាជន។ បទបង្ហាញរបស់គាត់បានផ្តោតជាពិសេសលើ៖ ទិដ្ឋភាពទូទៅនៃកម្មវិធីកំណែទំរង់ហិរញ្ញវត្ថុសាធារណៈ (PFMRP) វឌ្ឍនភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សកម្មភាពនាពេល អនាគតនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ផែនការសកម្មភាពដំណាក់កាលទី៣ (CAP3)។ ជាបឋម លោក សេនសាន បានជំរាបជូនអ្នកចូលរួមអំពីទិដ្ឋភាពទូទៅនៃកម្មវិធីកំណែទំរង់ហិរញ្ញវត្ថុសាធារណៈដោយបានលើកឡើងថា ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាការគ្រប់គ្រងដែលមានលក្ខណៈជាប្រព័ន្ធមួយដែលរៀបចំឡើងដើម្បី ធានាថា ការវិភាជន៍ និងការប្រើប្រាស់ថវិកាក្នុងរបៀបដែលមានប្រសិទ្ធិភាព និងប្រសិទ្ធិផល។ លោក សេនសាន បានលើកឡើងបន្ថែមទៀតថា ការកែទំរង់ហិរញ្ញវត្ថុសាធារណៈ គឺជាការធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុទាំងមូលជាបណ្តើរៗ ដោយផ្តោតលើការត្រួតពិនិត្យតាមដានលើ ធាតុចូល និងសង្កត់ធ្ងន់លើការត្រួតពិនិត្យ និងវាយតម្លៃលើលទ្ធផល (outcomes) និងវិមជ្ឈការ។ លោក សេនសាន បានចង្អុល បង្ហាញថាកម្មវិធីកំណែទំរង់ហិរញ្ញវត្ថុសាធារណៈ (PFMRP) គឺជាកម្មវិធីរបស់រដ្ឋាភិបាលដែលការជោគជ័យរបស់កម្មវិធីកំណែទំរង់នេះ អាស្រ័យលើប្រសិទ្ធិភាព និងប្រសិទ្ធិផលនៃការអនុវត្តន៍ដោយជោគជ័យរបស់សាមីក្រសួង និងស្ថាប័នទាំងអស់។

បន្ទាប់មក លោក សេនសាន បានគូសបញ្ជាក់ពីវឌ្ឍនភាព និងសមិទ្ធិផលសំខាន់ៗ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមមាន៖ (១) ភាពជឿទុកចិត្តបាននៃថវិកា (២០០០-២០០៨) (២) គណនេយ្យភាពហិរញ្ញវត្ថុ (២០០៩-២០១៥) និង ការផ្សាភ្ជាប់ថវិកា និងគោលនយោបាយ (២០០៨-២០២០)។ លោក បានលើកឡើងថា ជាងមួយទសវត្សរ៍ចុងក្រោយនេះ កម្មវិធីនេះសម្រេចបាននូវវឌ្ឍនភាពគួរឲ្យកត់សម្គាល់ ដូចជា៖ (១) ការប្រមូលចំណូល និងការគ្រប់ គ្រងចំណាយ ត្រូវបានពង្រឹង ព្រមទាំង ការទូទាត់ថវិកាលឿនជាងមុន (អាចជឿជាក់បាន) (២) ការកត់ត្រា និងការធ្វើរបាយការណ៍ហិរញ្ញវត្ថុបាន និងកំពុងត្រូវបានពង្រឹងត្រឹមត្រូវច្បាស់លាស់ ទាន់ពេលវេលា និងសុក្រឹត (ការបង្កើនគណនេយ្យភាព និងតម្លាភាពព័ត៌មានហិរញ្ញវត្ថុ) និង (៣) ការអនុវត្តន៍ផែនការយុទ្ធសាស្ត្រថវិកា ថវិកាកម្មវិធី និងអង្គភាពថវិកាបាននឹងកំពុងបង្កើនការផ្សាភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ព្រមទាំងជាមូលដ្ឋានសម្រាប់ការវិភាជន៍និងប្រើប្រាស់ថវិកាកាន់តែមានស័ក្តិសិទ្ធិភាព និងប្រសិទ្ធិភាព។

ជាចុងក្រោយ លោក សេនសាន បានបង្ហាញពីផែនការអនាគតរបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាពិសេស ផែនការ សកម្មភាពដំណាក់កាលទី៣ (CAP3)។ ផែនការសកម្មភាពដំណាក់កាលទី៣ នេះ រួមបញ្ចូល ៥ផ្នែក ដូចជា៖ (១) បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា (២) បន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ (៣) ការផ្សាភ្ជាប់ថវិកាទៅនឹងគោលនយោបាយ (៤) ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់ និង (៥) ការគាំទ្រដល់ការអនុវត្តន៍កម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព។ ជាចុងបញ្ចប់ លោក សេនសាន បានបញ្ជាក់ថា ផែនការសកម្មភាព ដំណាក់កាលទី៣ នេះ ត្រូវបានរៀបចំឡើងឲ្យមានសកម្មភាពមួយចំនួនដោយធ្វើការពាក់ព័ន្ធជាមួយសាធារណៈ ជន រួមមាន៖ (១) កែលម្អការប្រកួតប្រជែង និងតម្លាភាពនៅក្នុងដំណើរការលទ្ធកម្មដោយអនុញ្ញាត្តិឲ្យមានការ ចូលរួមពីសាធារណៈជន និងដំណើរការបើកទូលាយ ក៏ដូចជាការបិទផ្សាយជាសាធារណៈនូវផែនការលទ្ធកម្មប្រចាំឆ្នាំ និងការប្រគល់កិច្ចសន្យា និង (២) កែលម្អទម្រង់របាយការណ៍ និងការផ្លាស់ប្តូរព័ត៌មានជាមួយ សាធារណៈជន។ *សូមមើលព័ត៌មានលំអិតនៅក្នុងឧបសម្ព័ន្ធនៃបទបង្ហាញស្តីពី កំណែទំរង់ហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ ផ្តោតលើតម្លាភាពថវិកា និងការចូលរួមរបស់ប្រជាជន។*

## ៤.២ ការពិភាក្សាអំពីដំណើរការ ផ្លូវឆ្ពោះទៅរកការធ្វើឲ្យប្រសើរឡើងនូវតម្លាភាពថវិកានៅក្នុងប្រទេសកម្ពុជា

បន្ទាប់ពីបទបង្ហាញរបស់លោក សេនសាន វាគ្មិនផ្តល់យោបល់ត្រលប់ត្រូវបានសំណូមពរឲ្យផ្តល់នូវមតិយោបល់អំពីថាតើ ត្រូវកែលម្អតម្លាភាពថវិកាដោយរបៀបណានៅកម្ពុជា។ លោក ហ្សាវារ បានលើកឡើងថា មុននឹងបោះពុម្ពផ្សាយរបាយការណ៍ វាជាបុរេលក្ខខណ្ឌដែលថារដ្ឋាភិបាលអាចផលិតរបាយណ៍ ទាំងនោះជាមុនសិន។ ការផលិតរបាយការណ៍ទាំងនេះ ត្រូវឆ្លងកាត់ដំណើរការវែងឆ្ងាយ (មិនមែនមួយយប់ឡើយ) ព្រោះថា

រដ្ឋាភិបាលបានបំពេញការងារក្នុងការគ្រប់គ្រងថវិកាជាច្រើនដូចជា៖ តារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ របាយការណ៍ចុងឆ្នាំ និងរបាយការណ៍សាវនកម្ម ដែលតម្រូវឲ្យមានប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុដ៏ល្អមួយ។ លោក ហ្សាវារ បានលើកឡើងថា ផែនការសកម្មភាពដំណាក់កាលទី ៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានផលិតទាន់ពេលវេលា។ សហគមន៍អឺរ៉ុប និង ដៃគូអភិវឌ្ឍន៍ដែលពាក់ព័ន្ធត្រូវបានអញ្ជើញឲ្យចូលរួមផ្តល់មតិយោបល់ ទៅលើផែនការ សកម្មភាពដំណាក់កាលទីនៃកម្មវិធីកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នេះ។ លើសពីនេះ លោក ហ្សាវារ បានសង្កត់ធ្ងន់ថា វាមានសារៈសំខាន់ណាស់ដែលថា អាជ្ញាធរសាវនកម្មជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋសភាជាតិ ធ្វើការរួមគ្នា ដើម្បីស្វែងរកវិធីក្នុងការកែលម្អព័ត៌មាន និងការគ្រប់គ្រងថវិកា។ លោក ហ្សាវារ បានបន្ថែមថា អង្គការសង្គមស៊ីវិល (ឧ. ក្រុមការងារថវិការបស់អង្គការមិនមែនរដ្ឋាភិបាល) គឺមានសារៈសំខាន់ណាស់ ដែលគប្បីរាប់បញ្ចូលនៅក្នុងដំណើរការនេះ។ ជាចុងក្រោយ លោក ហ្សាវារ បានលើកឡើងថា វាមានសារៈ ប្រយោជន៍ណាស់ ដែលត្រូវជម្រាបជូនរដ្ឋាភិបាលអំពីឯកសារដែលមិនបានបោះពុម្ពផ្សាយ ព្រមទាំងរៀបចំឲ្យ មានកិច្ចសន្ទនាក្នុងន័យស្ថាបនា ទៅលើរបៀបក្នុងការកែលម្អតម្លាភាព និងគណនេយ្យភាពថវិកា។

លោកបណ្ឌិត វណ្ណារ៉ា នាយកប្រតិបត្តិនៃអង្គការ NGO Forum បានផ្តល់មតិយោបល់ទៅលើរបៀបដើម្បីកែលម្អតម្លាភាពថវិកា។ ជាដំបូង គាត់បានបញ្ជាក់ឡើងវិញថា របកគំឃើញនៃការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា បង្ហាញថារដ្ឋាភិបាលបានផលិតឯកសារថវិកាមួយចំនួនសម្រាប់ប្រើប្រាស់ផ្ទៃក្នុង ដែលជាជំហានដ៏ល្អមួយ ក្នុងកែលម្អនាពេល អនាគត។ លើសពីនេះទៀត វានឹងកាន់តែប្រសើរ ប្រសិនបើរដ្ឋាភិបាល ជាពិសេស ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុពិចារណាថាតើប្រភេទព័ត៌មានថវិកាបែបណាអាចបើកចំហរឲ្យកាន់តែទូលាយសម្រាប់សាធារណជនទូទៅ។ ធ្វើដូចនេះ ប្រជាពលរដ្ឋ និងសង្គមស៊ីវិលអាចចូលរួមនៅក្នុងដំណើរការថវិកា និងចូលរួមចំណែកក្នុងការតាមដានថវិកា ដែលអាចចូលរួមចំណែកក្នុងការធ្វើឲ្យមានគណនេយ្យភាពថវិកា។ លោកបណ្ឌិត វណ្ណារ៉ា បានចង្អុលបង្ហាញថា ច្បាប់ថវិកាហាក់ដូចជារឹតត្បិតនូវការចូលរួមរបស់សាធារណៈជន។ ហេតុដូចនេះ វាកាន់តែល្អប្រសើរប្រសិនបើច្បាប់នេះត្រូវបានធ្វើវិសោធនកម្មដើម្បីពង្រីកវិសាលភាពឲ្យមានការចូលរួមពី សាធារណជននៅក្នុងដំណើរការថវិកា។ ជាចុងក្រោយ លោកបណ្ឌិត វណ្ណារ៉ា បានផ្តល់យោបល់ថា ព័ត៌មានថវិកាលំអិតបន្ថែមទៀត នៅថ្នាក់ឃុំ ថ្នាក់ស្រុក និងថ្នាក់ខេត្ត គប្បីផ្សព្វផ្សាយជាសាធារណៈ ឲ្យកាន់តែទូលំទូលាយ។ ការចែកផ្សាយព័ត៌មានថវិកាបែបនេះនៅថ្នាក់មូលដ្ឋាន នឹងជួយជម្រុញឲ្យប្រជាជននៅថ្នាក់ មូលដ្ឋាន ចូលរួមនៅក្នុងការអភិវឌ្ឍតំបន់របស់ពួកគាត់។

### សំណួរ និងមតិយោបល់៖

លោក ជា គឹមសុង មកពី អង្គការ UNICEF បានចូលរួមផ្តល់មតិយោបល់ទៅលើថាតើនឹងត្រូវ កែលម្អតម្លាភាពថវិកាដោយរបៀបណា។ លោក គឹមសុង បានលើកឡើងថា ថ្មីៗនេះ នាយកដ្ឋានស្ថិតិនៃក្រសួង

សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គការ UNICEF បានពិភាក្សាគ្នា ក្នុងត្រួតពិនិត្យទៅលើនិតិវិធី និង ដំណើរការនៃការផលិតព័ត៌មានហិរញ្ញវត្ថុ រួមមានទាំងតារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈផងដែរ។ នៅក្នុងដំណើរការត្រួតពិនិត្យនេះ គេរកឃើញថា កង្វះខាតនូវបុគ្គលិកដែលមានសមត្ថភាព និងធនធានមនុស្សមិនគ្រប់គ្រាន់ បានធ្វើឲ្យមានបញ្ហាប្រឈមក្នុងការផលិតនូវព័ត៌មាន និងរបាយការណ៍ហិរញ្ញវត្ថុ។ លើសពីនេះទៀតដើម្បីផលិតចេញនូវរបាយការណ៍ តារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ វាចាំបាច់ត្រូវមានកិច្ចសហការក្នុងចំណោមនាយកដ្ឋានផ្សេងៗរួមមាន៖ អគ្គនាយកដ្ឋានរតនាគាជាតិ (General Department of National Treasury) អគ្គនាយកដ្ឋានថវិកា (General Department of Budget) ធនាគារជាតិនៃកម្ពុជា (National Bank of Cambodia) និង ក្រុមប្រឹក្សាអភិវឌ្ឍន៍នៃកម្ពុជា (the Cambodia Development Council)។ ហេតុដូចនេះ វាហាក់ដូចជាមិនងាយស្រួលទេ ក្នុងការរៀបចំរបាយការណ៍តារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈនេះ ព្រោះថា ការផលិតរបាយការណ៍នេះ ពាក់ព័ន្ធទៅនឹងការសម្របសម្រួល និងកិច្ចសហការពីនាយកដ្ឋាន និងស្ថាប័នដែលបានរៀបរាប់ខាងលើ។ លោក គឹមសុង ក៏បានបញ្ជាក់ថា កិច្ចការពិនិត្យមើលលើដំណើរការ និងនិតិវិធីនៃការផលិតរបាយការណ៍តារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ បានបញ្ចប់ដោយមានការដាក់ចេញនូវអនុសាសន៍មួយចំនួនក្នុងការបង្កើនតម្លាភាពថវិកា។ ដោយសារតែតម្លាភាពថវិកានៅក្នុងការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា ផ្តោតលើការចេញផ្សាយនូវព័ត៌មាន និងឯកសារថវិកា ជាចុងក្រោយ លោក គឹមសុង បានស្នើឡើងថា កិច្ចប្រជុំទៀងទាត់មួយរវាង ក្រុមការងារថវិការបស់អង្គការមិនមែនរដ្ឋាភិបាល និង លេខាធិការដ្ឋាននៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អាចត្រូវរៀបចំឡើងដើម្បីពិភាក្សាបញ្ហាជាក់លាក់មួយចំនួន ថាតើនឹងត្រូវកែលម្អតម្លាភាពថវិកាដោយរបៀបណា ហើយការធ្វើដូចនេះ នឹងអាចចូលរួមចំណែកក្នុងការធ្វើឲ្យកើនឡើងពិន្ទុនៃការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា នៅឆ្នាំខាងមុខ។

លោក ស្រី មុន្នី ដែលជាទីប្រឹក្សាឯករាជ្យ បានសួរទៅកាន់តំណាងរបស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុថាតើអនុសាសន៍នៃការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា នឹងត្រូវយកទៅពិចារណាដោយរបៀបណាក្នុងការរៀបចំ ផែនការCAP3 នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ?

**ចម្លើយ៖**

លោក សេនសាន តំណាងមកពី ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានឆ្លើយតបទៅនឹងសំណួររបស់លោក មុន្នី ថា ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងព្យាយាមធានាថាអនុសាសន៍ទាំងនោះត្រូវដាក់បញ្ចូលទៅក្នុងផែនការ CAP3 នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឲ្យបានច្រើនតាមតែអាចធ្វើទៅបាន។ លើសពីនេះទៀត រដ្ឋាភិបាលនឹងធ្វើការកែលម្អបន្ថែមលើកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប៉ុន្តែ កិច្ចការទាំងនេះ ត្រូវការពេលវេលា និង ចាំបាច់ត្រូវមានធនធានមនុស្សបន្ថែមទៀត។ លោក សេនសាន ក៏បានបញ្ជាក់

ផងដែរថា រដ្ឋាភិបាល បើកចំហចំពោះមតិយោបល់ ឬរបក គំហើញនៃអង្កេតការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា និងមតិយោបល់ដទៃទៀតពីដៃគូអភិវឌ្ឍន៍ ដើម្បីកែលម្អប្រព័ន្ធថវិកា។

# ៥. សន្ទរកថាបិទកម្មវិធី

លោកស្រី ទី សុភារី អនុប្រធានប្រចាំតំបន់ OXFAM បានសង្ខេបនូវកិច្ចពិភាក្សានៃអង្គសិក្ខាសាលាមួយព្រឹកដោយបានលើកឡើងនូវបីចំណុចសំខាន់ៗ ដែលគប្បីយកចិត្តទុកដាក់រួមមាន៖

(១) ការអង្កេតភាពបើកចំហថវិកា (OBS) វាយតម្លៃលើតម្លាភាព និងគណនេយ្យភាពថវិការបស់រាជរដ្ឋាភិបាលកម្ពុជា។ ហេតុដូចនេះ របកគំឃើញនៃការអង្កេតភាពបើកចំហថវិកានេះ អាចត្រូវបានប្រើប្រាស់ជាមគ្គុទ្ទេសន៍ដើម្បីពិនិត្យ និងកែលម្អការទទួលបានព័ត៌មានថវិកាសម្រាប់សាធារណៈជន ក៏ដូចជាបង្កើនគណនេយ្យភាពថវិកាបន្ថែមទៀតពីរដ្ឋាភិបាល។

(២) ការអង្កេតភាពបើកចំហថវិកា មានសារៈសំខាន់សម្រាប់កម្ពុជា ព្រោះថា លទ្ធផលនៃការអង្កេតភាពបើកចំហថវិកាអាចត្រូវប្រើប្រាស់ជាឧបករណ៍មួយដើម្បីចូលរួមចំណែក៖ (a) ការអនុវត្តន៍ការប្រយុទ្ធប្រឆាំងអំពើពុករលួយ (b) ទាក់ទាញវិនិយោគបរទេស ដែលជាកត្តាជំរុញឲ្យមានការពង្រឹងការអភិវឌ្ឍសេដ្ឋកិច្ច (c) ជំរុញលើកទឹកចិត្តឲ្យមានការចេញផ្សាយឯកសារថវិកាពាក់ព័ន្ធឲ្យទាន់ពេលវេលា និង (d) ពង្រឹងអភិបាលកិច្ចល្អ។ ជាចុងក្រោយ រាជរដ្ឋាភិបាលនឹងទទួលការទុកចិត្តពីប្រជាពលរដ្ឋ។

(៣) គេទទួលស្គាល់ថា រាជរដ្ឋាភិបាលបានពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីបង្កើនភាពជឿជាក់តម្លាភាព និង គណនេយ្យភាពថវិកា។ ទោះបីជាយ៉ាងណាក៏ដោយ កិច្ចខិតខំប្រឹងប្រែងទៅលើកិច្ចការទាំងនេះពិតជាត្រូវការពេលវេលាដើម្បីសម្រេចបានតាមការគ្រោងទុក ខណៈដែលកង្វះខាតធនធានមនុស្សនៅតែជាបញ្ហាប្រឈមយ៉ាងសំខាន់សម្រាប់រដ្ឋាភិបាល។

ជាចុងក្រោយ លោកស្រី សុភារី បានលើកឡើងថា យើងសង្ឃឹមថា រាជរដ្ឋាភិបាលនឹងពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីកែលម្អព័ត៌មាន តម្លាភាព និងគណនេយ្យភាពថវិកា។ បន្ទាប់មក លោកស្រី ថ្លែងអំណរគុណ ដល់អ្នកចូលរួម និងវាគ្មិនកិត្តិយសទាំងអស់ដែលបានចូលរួមយ៉ាងសកម្ម និងរួមចំណែកយ៉ាងផុសផុលក្នុងកិច្ចពិភាក្សានៃអង្គសិក្ខាសាលានាថ្ងៃនេះ។

## ៦.សេចក្តីសង្ខេបពីរបាយការណ៍សារពត៌មានសម្រាប់សិក្ខាសិលាផ្សព្វផ្សាយស្តីពីលទ្ធផលនៃការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា ឆ្នាំ ២០១៥

| លេខ | ឈ្មោះអ្នកសារព័ត៌មាន | ចំណងជើង និង ឯកសារភ្ជាប់ |
|---|---|---|
| ១ | Cambodia Daily | កម្ពុជាស្ថិតក្នុងដំណាក់កាលទី ៧ សម្រាប់ប្រទេសដែលមានតម្លាភាពថវិកាទាបបំផុត របាយការណ៍នៃរបកគំហើញ https://www.cambodiadaily.com/news/cambodia-seventh-worst-for-budget-transparency-report-finds-100652/ |
| ២ | The Phnom Penh Post | តម្លាភាពថវិកាទាបគ្រប់ពេលវេលា របាយការណ៍ http://www.phnompenhpost.com/national/budget-transparency-all-time-low-report |
| ៣ | RFA | "កម្ពុជាស្ថិតក្នុងចំណោមប្រទេសមានពិន្ទុទាបបំផុតលើតម្លាភាពថវិកា" http://www.rfa.org/khmer/news/politics/cam-found-low-score-in-budget-transparency-11172015225527.html |
| ៤ | RFI | កម្ពុជានៅតែស្ថិតក្នុងចំណោមប្រទេសមានពិន្ទុទាបបំផុតលើតម្លាភាពថវិកាក្នុងឆ្នាំ ២០១៥នេះ http://km.rfi.fr/cambodia/natioal-budget-17-11-2015 |
| ៥ | VOD | អង្គការមួយថាកម្ពុជាទទួលបានពិន្ទុទាបសម្រាប់តម្លាភាពថវិកាជាតិ http://vodhotnews.com/33329 |
| ៦ | The Khmer Times | តម្លាភាពថវិការបស់កម្ពុជាគួរឲ្យសង្វេគ របកគំហើញនៃការអង្កេត |

| លេខ | ឈ្មោះអ្នកសារព័ត៌មាន | ចំណងជើង និង ឯកសារភ្ជាប់ |
|---|---|---|
| | | http://www.khmertimeskh.com/news/17911/cambodia---s-budget-transparency-dismal--survey-finds/ |
| ៧ | Khmer Daily | កម្ពុជាមានពិន្ទុទាបទៅលើតម្លាភាពថវិកា http://thekhmerdaily.com/homepage/detail/33010 |
| ៨ | RFI | រដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថាកម្ពុជាពិតជាទទួលបានពិន្ទុទាបខាងផ្នែកតម្លាភាពថវិកាជាតិ ហើយព្រមទទួលយកចំណុចកែលម្អ http://km.rfi.fr/teuk-vannara-talk-about-national-buget-17-11-15?ns_campaign=reseaux_sociaux&ns_source=FB&ns_mchannel=social&ns_linkname=emission&aef_campaign_ref=partage_user&aef_campaign_date=2015-11-17 |
| ៩ | VOY |  VOY voice.MP3 |
| ១០ | Comfrel | តម្លាភាពនៅកម្ពុជា http://www.ustream.tv/recorded/78066384 |

# Report on

## LAUNCHING WORKSHOP ON THE OPEN BUDGET SURVEY 2015: FININGS FOR CAMBODIA

**Venue: Tonle Bassac II Restaurant**

**Date and Time: November 17 2015, 08:00am –12:00pm**




### ORGANIZING COMMITTEE

The NGO Forum on Cambodia

TRANSPARENCY INTERNATIONAL Cambodia

Save the Children

CAMBODIANS FOR RESOURCE REVENUE TRANSPARENCY

OXFAM

API BUILDING CAPACITY FOR CHANGE

DPA

GADC

### SUPPORTED BY:

OXFAM

unicef

# Table of Contents


**1. Introduction and objective of the launching workshop** .... 1

**2. Welcome and Opening Remarks** .... 1

**3. Session 1: Findings of open budget survey 2015 in Cambodia** .... 4

**3.1 Presentation of the OBS result for Cambodia in 2015: what is OBS, methodology, finding and recommendations** .... 4

**3.2 Feedback from panelist** .... 6

**4. Session 2: Discussion on way forward to improve budget transparency in Cambodia** .... 9

**4.1 Presentation of the PFMR stage 3: Budget Transparency and public participation** .... 9

**4.2 Panel discussion on how to improve budget transparency in Cambodia** 10

**5. Closing remark** .... 12

**6. Summary of Media Reports on OBS 2015 Launching Workshop** .... 13

**7. Appendix**

Appendix 1: Agenda of OBS 2015 launching workshop....13

Appendix 2: List of Participants....16

Appendix 3: OBS 2015 slide presentation....20

Appendix 4: Slide presentation on PFMR stage....32

Appendix 5: OBS 2015 launching workshop report....38

## Report of Workshop on

## LAUNCHING WORKSHOP ON THE OPEN BUDGET SURVEY 2015: FININGS FOR CAMBODIA

# 1. Introduction and objective of the launching workshop

NGO Forum on Cambodia (NGOF) has been facilitating the Open Budget Survey (OBS) since 2008 to advocate for budget transparency and credibility in Cambodia. The level of budget transparency in Cambodia was assessed at 15 out of 100 scores in 2010 and 2012 and it has 7 points dropped by 2015. This is the fourth round for Cambodia to participate in OBS. The OBS 2015 is also the same as the previous OBS that evaluate three pillars of budget transparency and accountability: it considers the extent to which national or central governments provide the public with timely and comprehensive access to eight key budget documents required by international good practices ; the degree to which opportunities for public participation in the budget process are present; and examines ability of legislatures and supreme audit institutions to provide effective oversight of government budgets.

The main purposes of the launching workshop on the Open Budget Survey (OBS) 2015 consist of: (i) presenting the findings of OBS 2015 for Cambodia, and (ii) creating the dialogue platform for budget transparency and accountability, and finding better solutions to improve the transparency and accountability in Cambodia.

# 2. Welcome and Opening Remarks

## 2.1 Welcome remark

In the welcome remarks, Dr. Tek Vannara, Executive Director of the NGO Forum on Cambodia (NGOF) and on behalf of the organizing committee[1], firstly thanked participants and panelists for their attendance in the launching workshop on open budget survey 2015. He then stated that national budget is the Cambodian citizens' budget, which results from their efforts in paying tax and other service fees in the present time as well as in the future to contribute to the state's revenue and debt payments borrowing on behalf of the

[1] The organizing committee of this launching workshop include: API, CRRT, NGO Forum, Oxfam, Save the Children, GADC, DPA and TIC.

Cambodian citizens. This ownership means that all Cambodian citizens are entitled to be aware of how their money is collected and used. In this sense, the government, who manages those budgets and provides public services for citizens, is obligated to report the relevant budget information to citizens.

Dr. Vannara stressed that budget transparency is significant for the government to combat corruption through participation of CSOs and the general public to supplementary monitoring the management of national budget in order to reduce and avoid the loss of national resources. Thus, these resources could be effectively invested in the priority sectors including health, education, agricultures, and rural development, etc. To ensure that national budget is managed to meet the present priority needs, and invest in the right direction for the future generation in efficient, effective and equitable manner, all decisions involved with national budget are necessary to be transparent, accountable, and participation from all relevant stakeholders, Dr. Vannara further raised.

Dr. Vannara finally reported that the Open Budget Survey (OBS) scores Cambodia 8 points out of 100. Along with this low level of score, he eventually provided several recommendations to improve budget transparency in the future including: (i) strengthening budget transparency through promoting draft annual budget law, promoting mid-year report, disseminating citizen budget and end-year report in a timely manner, (ii) enhancing public participation in budget process, and (iii) strengthening the budget oversight by: a) establishing parliamentary budget office which provides technical skills for legislative body, b) in law and practice, ensure the legislature is consulted prior to the spending of contingency funds that were not identified in the Enacted Budget, and c) ensure the supreme audit institution has adequate funding to perform its duties, as determined by an independent body.

## 2.2 Key note address

Mr. Javier CASTILLO-ALVAREZ, Delegation of the European Union to the Kingdom of Cambodia, provided a key note address by initially highlighting that transparency is important part for Public Financial Management Reform Program (PFMRP). Mr. Javier then pointed out the overview of PFMRP, which consists of four platforms: (i) budget is credible because delivers reliable and predictable resource to budget managers, (ii) initial

improvements in internal control and holding managers accountable, (iii) improved linkage between economic and policy priorities as well as service targets to budget planning and implementation, and (iv) integration of accountability and review processes for both finance and performance. He stressed that transparency does not only contribute to improving accountability, but also to facilitating foreign investment because the private sectors are willing to invest and do business with the transparent government. Moreover, both international and local companies are more willing to participate in transparent public procurement process, which promotes competitiveness and value of money, and thus improving public services for citizens.

He then stated that it is very crucial for the government to inform the public about what the government is doing; otherwise, the citizens will not be aware of the progress of what the government has achieved. For instance, the Public Expenditure of Financial Accountability (PEFA) Assessment reveals that the government of Cambodia is now able to produce Tableau d'Opération Financière de l'Etat (TOFE) or Table of Public Financial Operation in a comprehensive way, and produce the report in two weeks after the reporting period. Nevertheless, he mentioned that it is doubtful that the 2015 OBS shows that the report of TOFE was not published in time. Therefore, it is wondering that the government can produce such report within two weeks after the reporting period, but not publicize later than three months after the reporting period ends. Thus, such thing can be brought for discussion in this forum later.

Mr. Javier finally mentioned that the budget transparency needs to be enhanced so that the public will be aware of how the government spends public finances. In addition, he argued that transparency is not only about the release or publications of the budget documents/ reports, but also taken into account of financial reliability, and accountability of the government institutions in general. Therefore, these things should be taken into consideration into the OBS survey. Since the OBS survey was conducted in 2014, Mr. Javier also would like to discuss any progress made on the PFMRP from end of 2014 because he observes that there has been progress made on this after period. He also stated that it is important to look forward and use the 2015 OBS survey as a baseline on how to improve budget transparency both short and long-term. He eventually congratulated the NGO

Budget Working Group to take initiative to organize this dialogue and work together to improve Cambodia's budget transparency and accountability.

# 3. Session 1: Findings of open budget survey 2015 in Cambodia

This session was moderated by Mr. Pen Raksa, Transparency International Cambodia, while Dr. Tek Vannara was a key speaker on findings of open budget survey 2015 in Cambodia. Meanwhile, H.E. Son Chhay, Vice-Chairman of Commission II of the National Assembly, Mr. Lay Sok Khean, Deputy Director of the Budget Department, Mr. Javier CASTILLO-ALVAREZ, was the key commentators.

## 3.1 Presentation of the OBS result for Cambodia in 2015: what is OBS, methodology, finding and recommendations

Dr. Tek Vannara gave a presentation on the content of the slides, highlighting three main points, which contained: (i) the introduction to OBS and methodology of OBS, (ii) findings of global and Cambodia's OBS, and (iii) key recommendations.

Dr. Vannara firstly stated that the OBS 2015 monitors and evaluates three aspectsregarding the way by which the government of a country manages its public finance. The three aspects include budget transparency, public participation in budget process, and budget oversight. He then briefed the participants about the methodologies of OBS, which has five consecutive stages consisting of: (i) country experts' complete survey, (ii) International Budget Partnership (IBP) reviews the survey, (iii) external experts review the survey, (iv) the government reviews the survey, and (v) IBP reviews the final version of the survey. This survey's process lasts for 18 months. The OBS survey includes 140 questions, and uses 109 indicators to measure budget transparency. Specifically, these indicators are employed to assess whether the central government makes eight key budget documents[2] available to the public in a timely manner and whether the data contained in these documents are comprehensive and useful. In addition, 16 indicators are measure the opportunities for the

[2] The eight budget documents consist of: 1) pre-budget statement, 2) executive's budget proposal, 3) enacted budget, 4) citizen budget, 5) in-year reports, 6) mid-year review, 7) year-end report, and 8) audit report.

public to participate in the budget process and other 16 indicators evaluate the strength of the legislature and auditor (Detail information see in appendix 3).

Dr. Vannara secondly presented the global finding of the OBS by highlighting that the large majority of the world's population lives in countries that provide insufficient budget information. Between 2012 and 2015, the world made modest progress towards greater transparency. The problems associated with a lack of transparency are compounded by inadequate public participation and weak formal oversight. The findings show that the average score for public participation is just 25 out of 100. Meanwhile, legislative body of 66 countries faces serious deficiencies in their ability to oversee budget. Also, one-third of 102 countries, legislatures are not provided sufficient time to review the budget proposal before it is passed.

With regards to the Cambodia's findings of the OBS, Dr. Vannara reported that while it is the fourth round for Cambodia to carry out the OBS[3] starting from 2008. The results of this 2015 OBS for Cambodia were based on the information collected in 2014. If compared to the global scores, Cambodia is scored 8 out of 100 points. The 2015 Open Budget Index (OBI) score of Cambodia has decreased by 7 points, if compared to 2012 OBI score, which accounted for 15 scores. The Cambodia's score of 8 out of 100 scores shows that the provision of opportunities for the public to engage in the budget process is weak. This score also implies that the government provides the public with scant information on the central government budget and financial activities. This seems to make citizens difficult to hold the government accountable for its management of public monies including revenue collection and the public funds. In addition, Dr. Vannara highlighted that the legislative body and the supreme audit institution provide limited budget oversight.

It should be noted that the Cambodia's score is the second lowest after Myanmar, which receives scoring 2. Among the member states of the ASEAN, the Philippines gains the highest score (64), followed by Indonesia (59) and Malaysia (46). Finally, Dr. Vannara provided a number of recommendations for improving budget transparency, public participation in budget process, and budget oversight from legislature and audit institution. *Please see more detail in the slide presentation of Dr. Vannara in appendix 3.*

[3] The Open Budget Survey is carried out by the NGO Forum on Cambodia.

## 3.2 Feedback from panelist

២០១៦-២០២០: ចាប់ផ្តើមដំណាក់កាលទី៣ ដោយផ្តោតលើការកសាងប្រព័ន្ធថវិកាផ្តោតលើ លទ្ធផល និងវិមជ្ឈការឱ្យបានពេញលេញ និងជាបណ្តើរៗចាប់ផ្តើមសាកល្បងប្រព័ន្ធគ្រប់គ្រងដោយសមិទ្ធកម្ម

២០២១-២០២៥: ចាប់ផ្តើមដំណាក់កាលទី ៤ គឺគណនេយ្យភាពសមិទ្ធកម្ម ដោយផ្តោតលើការកសាង ប្រព័ន្ធគ្រប់គ្រងដោយសមិទ្ធកម្មពេញលេញ

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

10

## ៤. ផែនការសកម្មភាពរួមដំណាក់កាលទី៣ (CAP 3)

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

11

## ៤. ផែនការសកម្មភាពរួមដំណាក់កាលទី៣ (CAP 3)




- ផ្នែកទី ១ បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា
- ផ្នែកទី ២ បន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ
- ផ្នែកទី ៣ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ
- ផ្នែកទី ៤ ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់
- ផ្នែកទី ៥ ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

12

Appendix 4: Slide Presentation on PFMR stage 3












# Appendix 4: Slide Presentation on PFMR stage 3

## ៤. ផែនការសកម្មភាពរួមដំណាក់កាលទី៣ (CAP 3)

**ផ្នែកទី៥÷ ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព**

•ភាពជាអ្នកដឹកនាំ សមត្ថភាពគ្រប់គ្រង សមត្ថភាពបច្ចេកទេស ភាពជាម្ចាស់ ការទទួលខុសត្រូវ មានសមានគតិភាពជាមួយនឹងការគាំទ្រការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ






## ៤. ផែនការសកម្មភាពរួមដំណាក់កាលទី៣ (CAP 3)

| ផ្នែក | គោលបំណង/ ចង្កោមសកម្មភាព | គោលដៅ |
|---|---|---|
| ផ្នែកទី ១÷ បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា | 4/13 | -ការអនុវត្តចំណូល និងចំណាយប្រចាំត្រីមាសមានភាពរលូននិងអាចប៉ាន់ស្មានបាន (កម្រិតលម្អៀងនៃការអនុវត្តមិនលើសពី+/-៥% ធៀបទៅនឹងកម្មវិធីចំណូល-ចំណាយ)<br>-ការគ្រប់គ្រងបំណុលត្រូវសង និងបំណុលត្រូវទារក្នុងឆ្នាំប្រកបដោយប្រសិទ្ធភាព |
| ផ្នែកទី ២÷ បន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ | 4/15 | -ប្រព័ន្ធ យន្តការ ក្របខ័ណ្ឌគតិយុត្តត្រូវបានដាក់ឱ្យអនុវត្តប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពត្រឹមឆ្នាំ២០១៨ (ចំណាត់ថ្នាក់ថវិកា ប្លង់គណនី ការអនុវត្ត FMIS ដំណាក់កាលទី១ និងដំណាក់កាលទី២)<br>-ប្រព័ន្ធគណនេយ្យនិងប្រព័ន្ធកត់ត្រា និងប្រព័ន្ធរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុវត្តប្រកបដោយ ស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាព តម្លាភាព សុក្រឹតភាព និងទាន់ពេលវេលា |
| ផ្នែកទី ៣÷ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ | 6/22 | - ក្របខ័ណ្ឌថវិការយៈពេលមធ្យម (ដែលរួមមានក្របខ័ណ្ឌចំណូលរយៈពេលមធ្យម ក្របខណ្ឌចំណាយ រយៈពេលមធ្យម និងក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ) ត្រូវបានរៀបចំ និងដាក់ជូនគណៈរដ្ឋមន្ត្រី ពិនិត្យនិងអនុម័ត<br>- ផែនការយុទ្ធសាស្ត្រថវិកាត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តប្រកបដោយស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាព<br>- ថវិកាកម្មវិធីនិងអង្គភាពថវិកា ត្រូវបានដាក់ឱ្យអនុវត្តនៅគ្រប់ក្រសួងស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិប្រកបដោយ ស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាព |
| ផ្នែកទី ៤÷ ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់ | 4/9 | -ក្របខ័ណ្ឌថវិកា ក្របខ័ណ្ឌគណនេយ្យភាព និងក្របខ័ណ្ឌសវនកម្ម ដោយផ្អែកលើសមិទ្ធកម្មត្រូវបានរៀបចំ |
| ផ្នែកទី៥÷ ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព | 3/8 | -ភាពជាអ្នកដឹកនាំ សមត្ថភាពគ្រប់គ្រង សមត្ថភាពបច្ចេកទេស ភាពជាម្ចាស់ ការទទួលខុសត្រូវ មានសមានគតិភាពជាមួយនឹងការគាំទ្រការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |



## ៤. ផែនការសកម្មភាពរួមដំណាក់កាលទី៣ (CAP 3)

**តម្លាភាព និងការចូលរួមរបស់សាធារណៈជន ?**

- **១៤.២.** បង្កើនការប្រកួតប្រជែង និងតម្លាភាពក្នុងដំណើរការលទ្ធកម្ម ដោយមានការចូលរួមជាសាធារណៈ និងបើកចំហរ ព្រមទាំងផ្សព្វផ្សាយជាសាធារណៈនូវផែនការលទ្ធកម្មប្រចាំឆ្នាំ និង ការប្រគល់កិច្ចសន្យា
- **២៣.២.** កែលម្អទម្រង់របាយការណ៍អនុវត្តថវិកា ដែលត្រូវផ្ញើទៅគណៈរដ្ឋមន្ត្រី នឹងស្ថាប័ននីតិបញ្ញត្តិ ។
- **២៣.៣** កែលម្អទម្រង់របាយការណ៍និងការផ្លាស់ប្តូរព័ត៌មានជាមួយសាធារណជន (ក្រសួង ស្ថាប័ន)
- **២៣.៤.** ដាក់ឱ្យអនុវត្តយន្តការដើម្បីបញ្ចប់ការចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និងធ្វើបច្ចុប្បន្នភាពជាប្រចាំ




- **២៤.១.** បង្កើតឱ្យមានទណ្ឌកម្មរដ្ឋបាលសមស្រប ចំពោះកំហុសឆ្គង ឬការគ្រប់គ្រងធនធាន សាធារណៈមិនសមស្រប និងគ្មានប្រសិទ្ធភាព ។ ទណ្ឌកម្មនេះត្រូវចែងនៅក្នុងលិខិតបទដ្ឋានគតិយុត្ត និង ធ្វើការផ្សព្វផ្សាយ និងណែនាំឱ្យបានទូលំ ទូលាយ
- **២៤.៤.** រៀបចំ និងដាក់ឲ្យអនុវត្តទម្រង់របាយការណ៍វឌ្ឍនភាពអនុវត្តថវិកាប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ (ក្រសួងស្ថាប័ន)
- **៣២.២.** បញ្ចូលចំណូល ចំណាយដែលនៅក្រៅ បរិបថថវិកា ទៅក្នុងថវិកាប្រចាំឆ្នាំ ដោយរួមទាំង ថវិកាដៃគូ (ក្រសួង ស្ថាប័ន)
- **៣៣.២.** កំណត់ឱ្យបានច្បាស់ពី បន្ទាត់គណនេយ្យភាពក្នុងការរៀបចំកម្មវិធីវិនិយោគសាធារណៈដើម្បីធានាសង្គតិភាពក្នុងថវិកាប្រចាំឆ្នាំ (កំណត់ពីការទទួលខុសត្រូវឱ្យបានច្បាស់លាស់រវាងក្រសួង- ស្ថាប័ននីមួយៗ រួមមាន កសហវ ក្រសួងផែនការនិងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា



## ៤. ផែនការសកម្មភាពរួមដំណាក់កាលទី៣ (CAP 3)

**EU Joint result framework :**

- Fiscal transparency enhancement,
- Enhanced adequacy and transparency of fiscal transfers to Sub-National Administrations (SNAs)

# Appendix 4: Slide Presentation on PFMR stage 3

## ៤. ផែនការសកម្មភាពរួមដំណាក់កាលទី៣ (CAP 3)

### ចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA)




21

## ៤. ផែនការសកម្មភាពរួមដំណាក់កាលទី៣ (CAP 3)

### ចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA)

| ចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ | ទទួលបានពិន្ទុខ្ពស់ជាងមុន | រក្សាបានពិន្ទុនៅដដែល | ទទួលបានពិន្ទុទាបជាងមុន |
|---|---|---|---|
| ក. ភាពជឿទុកចិត្តបាននៃថវិកា | PI-1 (B→A)<br>PI-2 (D→D+) | PI-3 (A) | PI-4 (C+→D+) |
| ខ. ភាពគ្រប់ជ្រុងជ្រោយ និងតម្លាភាពថវិកា | PI-8 (C+ →B) | PI-5 (C)<br>PI-7 (C)<br>PI-9 (C+) | PI-6 (B→C)<br>PI-10 (C→D) |
| គ១. គោលនយោបាយផ្សារភ្ជាប់ថវិកា | NO | PI-11 (A) | PI-12 (B→C+) |
| គ២. ភាពអាចប៉ាន់ប្រមាណបាន និងការត្រួតពិនិត្យការអនុវត្តថវិកា | PI-21 (D+→C) | PI-15 (D+)<br>PI-16 (C+)<br>PI-17 (C+)<br>PI-18 (D+) | PI-13 (B→C+)<br>PI-14 (C→D+)<br>PI-19 (C→D+)<br>PI-20 (C→D+) |
| គ៣. គណនេយ្យ ការកត់ត្រា និងរបាយការណ៍ | NO | PI-22 (C)<br>PI-25 (D+) | PI-23 (C→D)<br>PI-24 (C+→C) |
| គ៤. ការត្រួតពិនិត្យ និងសវនកម្មខាងក្រៅ | [PI-26, PI-27, PI-28] មិនមានការប្រៀបធៀប | | |
| ឃ. ការអនុវត្តរបស់ដៃគូអភិវឌ្ឍន៍ | D2. (D→D+) | D3. (D) | D1. (C→D) |
| **សរុប** | **៥** | **១២** | **១១** |

22

# សូមអរគុណ

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

23

អង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា

# ប្រទេសកម្ពុជា

| តម្លាភាពថវិកា (សន្ទស្សន៍នៃការផ្សព្វផ្សាយព័ត៌មាន ថវិកា) | | ការចូលរួមរបស់សាធារណៈជនក្នុងដំណើរការថវិកា | ការត្រួតពិនិត្យថវិកា | |
|---|---|---|---|---|
| **8** ក្នុងចំណោម 100 | រាជរដ្ឋាភិបាលកម្ពុជាផ្តល់ជូនដល់សាធារណៈជននូវព័ត៌មាន**មិនគ្រប់គ្រាន់**ស្តីពីសកម្មភាពថវិកានិងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលនៅថ្នាក់ជាតិនៅក្នុងកំឡុងពេលថវិកា។ | **8** ក្នុងចំណោម 100<br>រដ្ឋាភិបាលនៃប្រទេសកម្ពុជាបានផ្តល់ឱកាស **តិចតួច** សំរាប់សាធារណៈជនចូលរួមក្នុងដំណើរការថវិកា។ | **43** ក្នុងចំណោម 100<br>**ដោយអង្គនិតិបញ្ញត្តិ**<br>ការត្រួតពិនិត្យថវិកាដោយអង្គនិតិបញ្ញត្តិក្នុងប្រទេសកម្ពុជាគឺ**នៅមានកំរិត**នៅឡើយ ។ | **58** ក្នុងចំណោម 100<br>**ដោយសវនករ**<br>ការត្រួតពិនិត្យថវិកាដោយស្ថាប័នសវនកម្មជាន់ខ្ពស់ក្នុងប្រទេសកម្ពុជាគឺ**នៅមានកំរិត**នៅឡើយ ។ |

## តើការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាជាអ្វី?

ការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា គឺជាការផ្តួចផ្តើមស្រាវជ្រាវ និងការវិភាគតែមួយគត់ ដែលបានប្រើប្រាស់ឯកសារជាភស្តុតាង និងលក្ខណៈវិនិច្ឆ័យគោលបំណងដើម្បីធ្វើការវាយតម្លៃទៅលើសសរស្តម្ភទាំងបីរបស់តម្លាភាព និងគណនេយ្យភាពថវិកា។ ការស្រាវជ្រាវនេះធ្វើការសិក្សាលើ ៖

- វិសាលភាពដែលរដ្ឋាភិបាលថ្នាក់ជាតិ ឬ ថ្នាក់កណ្តាលផ្តល់ទៅសាធារណៈជននូវព័ត៌មានថវិកា ថាតើគ្រប់ជ្រុងជ្រោយ និងទាន់ពេលវេលាឬទេ ចំពោះឯកសារថវិកាសំខាន់ៗទាំងប្រាំបី ដែលជាតម្រូវការនៃការអនុវត្តល្អរបស់អន្តរជាតិ។
- វិសាលភាពដែលរដ្ឋាភិបាលថ្នាក់ជាតិ ឬ ថ្នាក់កណ្តាលផ្តល់ឱកាសឲ្យសាធារណៈជនចូលរួមក្នុងដំណើរថវិកាជាតិ
- សមត្ថភាពរបស់អង្គនីតិបញ្ញត្តិ និងស្ថាប័នសវនៈកម្មជាន់ខ្ពស់ ក្នុងការពិនិត្យថវិកាជាតិប្រកបដោយប្រសិទ្ធភាព។

ការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា គឺជាវាស់វែងដែលមានលក្ខណៈ ឯករាជ្យ អាចប្រៀបធៀប និងតែងតែធ្វើការវាស់វែងលើតម្លាភាព និងគណនេយ្យភាពថវិកា ដែលបានសិក្សាដោយសង្គមស៊ីវិលឯករាជ្យមានជំនាញថវិកា និងមិនស្ថិតនៅក្រោមការគ្រប់គ្រង របស់រដ្ឋាភិបាលប្រទេសណាមួយឡើយ ។ មូលដ្ឋានគ្រឹះនៃការអង្កេតនេះគឺផ្អែកទៅលើ ១៤០សំណួរដែលមាននៅក្នុងបញ្ជីសំណួរនៃការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា ។ ការអង្កេតនេះត្រូវបានធ្វើឡើងរៀងរាល់២ឆ្នាំម្តង ដើម្បីពិនិត្យឡើងវិញនូវវឌ្ឍនភាពដែលប្រទេសនីមួយៗសម្រេចបាន ។ ឆ្នាំ២០១៥ គឺជាការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាលើកទី៥ ដែលត្រូវបានធ្វើឡើងជាមួយប្រទេសចំនួន១០២ប្រទេស ។ សម្រាប់ប្រទេសកម្ពុជា នេះគឺជាការអង្កេតលើកទី៤ ។

លទ្ធផលឆ្នាំ២០១៥ គឺជាការឆ្លុះបញ្ចាំងទៅនឹងការស្រាវជ្រាវដែលបានធ្វើឡើង ដោយអ្នកស្រាវជ្រាវឯករាជ្យជំនាញថវិកាពីសង្គមស៊ីវិល ផ្អែកទៅលើទិន្នន័យដែលបានប្រមូលនៅក្នុងឆ្នាំ២០១៤។

# តម្លាភាពថវិកា (សន្ទស្សន៍នៃការផ្សព្វផ្សាយព័ត៌មានថវិកា)

ផ្តោតទៅលើលក្ខណៈវិនិច្ឆ័យ ដែលទទួលស្គាល់ដោយអន្តរជាតិ ដែលរៀបចំឡើងដោយអង្គការពហុភាគី ការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា ប្រើប្រាស់សូចនាករចំនួន ១០៩ ដើម្បីវាស់វែងតម្លាភាពថវិកា។ សូចនាករទាំងនេះត្រូវបានប្រើដើម្បីប៉ាន់ប្រមាណថាតើ មជ្ឈដ្ឋានរដ្ឋាភិបាលបង្ហាញព័ត៌មាននៃឯកសារថវិកាសំខាន់ៗចំនួន ០៨ ជូនដល់ សាធារណៈបានទាន់ពេលឬទេ និងថាតើទិន្នន័យដែលផ្ទុកក្នុងឯកសារទាំងនេះមានព័ត៌មានគ្រប់គ្រាន់ ព្រមទាំងមានសារៈប្រយោជន៍ប៉ុណ្ណា។

ប្រទេសនីមួយៗ ត្រូវបានផ្តល់ពិន្ទុមួយក្នុងចំណោមពិន្ទុ១០០ ដែលកំណត់ចំណាត់ថ្នាក់របស់ប្រទេសទាំងនោះ នៅក្នុងសន្ទស្សន៍នៃការផ្សព្វផ្សាយព័ត៌មានថវិកា ដែលជាការសិក្សាឯករាជ្យតែមួយគត់ដែលមានលក្ខណៈប្រៀបធៀបបាន របស់ពិភពលោកលើតម្លាភាពថវិកា។




ឯកសារថវិកាដែលអាចរកបានគ្រប់ពេលវេលា

| ឯកសារ | ២០០៨ | ២០១០ | ២០១២ | ២០១៥ |
|---|---|---|---|---|
| របាយការណ៍បុរេថវិកា | 🟡 | 🟢 | 🟢 | 🟢 |
| សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល | 🟡 | 🟡 | 🟡 | 🟡 |
| ថវិកាដែលបានអនុម័ត | 🟢 | 🟢 | 🟢 | 🟢 |
| របាយការណ៍ថវិកាសម្រាប់ប្រជា | 🔴 | 🔴 | 🔴 | 🔴 |
| របាយការណ៍ក្នុងឆ្នាំ | 🟢 | 🟢 | 🟢 | 🔴 |
| របាយការណ៍ពាក់កណ្តាលឆ្នាំ | 🟡 | 🟡 | 🟡 | 🟡 |
| របាយការណ៍បំណាច់ឆ្នាំ | 🟢 | 🟢 | 🔴 | 🔴 |
| របាយការណ៍សវនកម្ម | 🟡 | 🟡 | 🟡 | 🔴 |

កំណត់សំគាល់៖ 🔴 ឯកសារមិនបានរៀបចំ 🟡 ឯកសារមិនបានរៀបចំសម្រាប់ប្រើប្រាស់ផ្ទៃក្នុង 🟢 ឯកសារដែលបានផ្សាយជាសាធារណ:

### សារៈប្រយោជន៍នៃព័ត៌មានថវិកា តាមរយៈដំណើរវិវត្តន៍នៃថវិកា



**កំណត់ចំណាំ៖**លក្ខណៈវិនិច្ឆ័យខាងលើត្រូវបានប្រើប្រាស់ដើម្បីវាយការណ៍ពីសារៈប្រយោជន៍នៃឯកសារ នីមួយៗ ។ **មិនបានផលិត, ផលិតយឺត, ប្រើប្រាស់ផ្ទៃក្នុង, ខ្វះខាត, ទាបបំផុត, មានដែនកំនត់, ទំហំធំ, ទូលំទូលាយ**

អង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា

# ប្រទេសកម្ពុជា

ប្រទេសកម្ពុជាទទួលបាន៨ពិន្ទុ ក្នុងចំណោម ១០០ពិន្ទុ គឺទាបជាងពិន្ទុមធ្យម(៤៥ពិន្ទុ)សម្រាប់ប្រទេស ដែលបានចូលរួមធ្វើការអង្កេតទាំង១០២។

ពិន្ទុប្រទេសកម្ពុជា ដែលមានក្នុងសន្ទស្សន៍នៃការផ្សព្វផ្សាយព័ត៌មានថវិកាឆ្នាំ២០១៥ គឺទាបជាងពិន្ទុក្នុងឆ្នាំ២០១២។

ចាប់ពីឆ្នាំ២០១២ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាមានការថយចុះនៃការផ្តល់ព័ត៌មានថវិកាដូចជា៖

- មិនបានផ្សព្វផ្សាយរបាយការណ៍ប្រចាំឆ្នាំឲ្យទាន់ពេលវេលា។
- លើសពីនេះទៅទៀត រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា មិនបានផ្សព្វផ្សាយជាសាធារណៈ នូវឯកសារសំខាន់មួយចំនួនដូចជា ៖
- មិនបានផ្សព្វផ្សាយសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាលជាសាធារណៈ។
- មិនបានផ្សព្វផ្សាយរបាយការណ៍ពាក់កណ្តាលឆ្នាំជាសាធារណៈ។
- បានបង្កើតឯកសារស្តីពីថវិកាសម្រាប់ប្រជាពលរដ្ឋប៉ុន្តែមិនបានផ្សព្វផ្សាយដល់សាធារណៈជនឲ្យបានទាន់ពេលវេលា។

**ព័ត៌មានលម្អិតនៃឯកសារថវិកាទាំងប្រាំបី**

| **ដំណាក់កាលនៅក្នុងវដ្តថវិកា** | **ឯកសារថវិកា** | **ពេលវេលាដែលត្រូវផ្សព្វផ្សាយឯកសារដោយផ្អែកតាមការអនុវត្តល្អរបស់អន្តរជាតិ** |
|---|---|---|
| **ដំណាក់កាលរៀបចំថវិកា** | **ឯកសារទី១: របាយការណ៍បុរេថវិកា** ផ្តល់ព័ត៌មាន (លទ្ធផលម៉ាក្រូសេដ្ឋកិច្ចពីឆ្នាំមុន និងឆ្នាំបច្ចុប្បន្ន និងការប៉ាន់ប្រមាណនៃថវិកាឆ្នាំថ្មី ឬឆ្នាំសារពើពន្ធ) ដែលផ្សារភ្ជាប់រវាងគោលនយោបាយ និងថវិកា ។ ប្រទេសកម្ពុជាបានផ្សព្វផ្សាយសារាចរណែនាំរបស់រាជរដ្ឋាភិបាល ស្តីពីគោលការណ៍ណែនាំសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ថវិកា នៅក្នុងសៀវភៅរាជកិច្ច តាំងពីឆ្នាំ២០០៩ ដែលអាចរកជាវជាសារធារណៈ នៅក្នុងតម្លៃថោក ។ | **របាយការណ៍បុរេថវិកា** ត្រូវតែផ្សព្វផ្សាយ <u>**រយៈពេលមួយខែមុនពេលសេចក្តីព្រាងច្បាប់ថវិកា**</u> ត្រូវបានផ្ញើរជូនអង្គនីតិបញ្ញត្តិដើម្បីពិចារណា ។ |
| | **ឯកសារទី២: សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល** ជាឯកសារ ដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផ្ញើរជូនអង្គនីតិបញ្ញត្តិ ដើម្បី អនុម័ត ។ ឯកសារនេះគឺជាឧបករណ៍គោលនយោបាយដ៏ សំខាន់បំផុតរបស់រដ្ឋាភិបាល ព្រោះវាបង្ហាញថាតើរដ្ឋាភិបាល គ្រោងនឹងបង្កើនចំណូលតាមរយៈពន្ធដារ និងប្រភពចំណូល ផ្សេងទៀតយ៉ាងដូចម្តេច ព្រមទាំងបង្ហាញពីផែនការចំណាយថវិកាទាំងនោះ ដើម្បីគាំទ្រដល់បណ្តារអាទិភាពនានា រួមទាំងការបែងចែកថវិកាទៅវិស័យផ្សេងៗ ដើម្បីប្រែក្លាយគោលនយោបាយទៅជាសកម្មភាព ។ រាជរដ្ឋាភិបាលកម្ពុជាបង្កើត | សំណើរថវិការបស់ស្ថាប័ននីតិប្រតិបត្តិត្រូវតែផ្សព្វផ្សាយជូនដល់សារធារណៈ <u>**ខណៈពេលអង្គនីតិបញ្ញត្តិនៅតែកំពុងពិចារណា**</u> ឬ មុនពេល អង្គនីតិបញ្ញត្តិអនុម័តលើថវិកា ។ |

| | | |
|---|---|---|
| | ឯកសារនេះសម្រាប់ការប្រើប្រាស់ផ្ទៃក្នុងតែប៉ុណ្ណោះ ហើយមិនផ្សព្វផ្សាយជាសារធារណៈនោះទេ ខុសពីការអនុវត្តល្អរបស់អន្តរជាតិ ។ គួរកត់សម្គាល់ថា នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១០ សេចក្តីព្រាងច្បាប់ថវិកាឆ្នាំ២០១១ ត្រូវបានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋសភា ផ្តល់ជូនវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា តាមសំណើរ ។ ប៉ុន្តែ ចាប់តាំងពីឆ្នាំ ២០១១ មក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមិនបានបញ្ចេញឯកសារនេះទៀតទេ។ | |
| **ដំណាក់កាលអនុម័តថវិកា** | **ឯកសារទី៣: ថវិកាដែលបានអនុម័ត(ច្បាប់ថវិកា)**គឺជាថវិកាដែលត្រូវបានសម្រេចដោយអង្គនីតិបញ្ញត្តិ។ ឯកសារនេះក្លាយជាច្បាប់របស់កម្ពុជា ដែលផ្តល់សិទ្ធិអំណាចឲ្យស្ថាប័ននីតិប្រតិបត្តិ បង្កើនចំណូល ធ្វើការចំណាយ និងទូទាត់បំណុល ។ ឯកសារនេះក៏ផ្តល់ព័ត៌មានមូលដ្ឋាន សម្រាប់ការធ្វើការវិភាគថវិកាទាំងអស់នៅក្នុងឆ្នាំថវិកា។ ជាទូទៅច្បាប់ថវិកាគួរតែផ្តល់ជូនដល់សាធារណៈនូវទិន្នន័យចាំបាច់ ដែលត្រូវការដើម្បីវាយតម្លៃអាទិភាពគោលនយោបាយ ដែលបានលើកឡើងរបស់រដ្ឋាភិបាល និងដើម្បីឲ្យរដ្ឋាភិបាលទទួលខុសត្រូវ ។ ប្រទេសកម្ពុជាផ្សព្វផ្សាយច្បាប់ថវិកាប្រចាំឆ្នាំ ឬច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង នៅក្នុងសៀវភៅរាជកិច្ច ។ ប៉ុន្តែ ឯកសារនេះមិនមានព័ត៌មានលម្អិតកម្រិតកម្មវិធីសម្រាប់ការចំណាយនោះទេ។ | ច្បាប់ថវិកា ត្រូវតែផ្សព្វផ្សាយជូនសារធារណៈ: **<u>មិនឲ្យលើសបីខែ</u>** បន្ទាប់ពីច្បាប់នេះត្រូវបានអនុម័ត ដោយអង្គនីតិបញ្ញត្តិ ។ |
| **ដំណាក់កាលអនុវត្តថវិកា** | **ឯកសារទី៤: របាយការណ៍ក្នុងឆ្នាំ** ផ្តល់នូវសេចក្តីសង្ខេបនៃវឌ្ឍនភាពនៃការអនុវត្តថវិកា ដូចជា ព័ត៌មានអំពីចំណូលជាក់ស្តែងដែលប្រមូលបាន ការចំណាយជាក់ស្តែង និងបំណុលដែលបានទូទាត់ នៅចន្លោះពេលផ្សេងគ្នា នៅក្នុងឆ្នាំសារពើពន្ធ ។ របាយការណ៍ក្នុងឆ្នាំរបស់កម្ពុជារួមមាន ព្រឹត្តិប័ត្រស្ថិតិប្រចាំខែ និងតារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋ ស្តីពីវឌ្ឍនភាពនៃចំណូល និងចំណាយនៅក្នុងខែ និងឆ្នាំនីមួយៗ ។ ប៉ុន្តែ របាយការណ៍ទាំងនេះខ្វះព័ត៌មានលម្អិតសំខាន់មួយចំនួន ដូចជា ការបែងចែកចំណាយតាមក្រសួង ការពន្យល់លម្អិតពីភាពខុសគ្នារវាងចំណូលនិងចំណាយជាក់ស្តែង ធៀបនឹងផែនការ និងការធ្វើបច្ចុប្បន្នកម្មជាប្រចាំ ឬបញ្ចូលព័ត៌មានទៅលើគេហទំព័រ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ/គេហទំព័រ | របាយការណ៍ក្នុងឆ្នាំត្រូវតែផ្សព្វផ្សាយជូនដល់សារធារណៈ: **<u>មិនឲ្យលើសបីខែ</u>** បន្ទាប់ពីរយៈពេលធ្វើរបាយការណ៍បញ្ចប់។ |

| | | |
|---|---|---|
| | សារធារណៈដទៃទៀត។ សំខាន់ជាងនេះទៀត ព្រឹត្តិបត្តិស្ថិតិប្រចាំខែមិនបានផ្សព្វផ្សាយ ចាប់តាំងពីឆ្នាំ២០០៤មកម្លេះ ដោយសារការជួសជុលគេហទំព័រ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុឡើងវិញ ។ | |
| | **ឯកសារទី៥: របាយការណ៍ពាក់កណ្ដាលឆ្នាំ**ផ្ដល់នូវបច្ចុប្បន្នភាពទូលំទូលាយស្ដីពីការអនុវត្តថវិកា នៅពាក់កណ្ដាលឆ្នាំថវិកា។ ព័ត៌មាននៅក្នុងរបាយការណ៍នេះ អនុញ្ញាតិឲ្យមានការវាយតម្លៃពីលទ្ធផលសារពើពន្ធ របស់រដ្ឋាភិបាលធៀបនឹងផែនការដែលបានកំណត់នៅក្នុងច្បាប់ថវិកា។ របាយការណ៍នេះក៏អនុញ្ញាតិឲ្យរដ្ឋាភិបាល អង្គនីតិបញ្ញត្តិ និងសាធារណៈកំណត់ថាតើគួរធ្វើការកែតម្រូវចំណូលចំណាយ ឬកម្ចី ក្នុងអំឡុងពេល៦ខែចុងក្រោយ ឬមួយយ៉ាងណា។ នៅក្នុងប្រទេសកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធ្វើរបាយការណ៍ពាក់កណ្ដាលឆ្នាំសម្រាប់ការប្រើប្រាស់ផ្ទៃក្នុងតែប៉ុណ្ណោះ។ វាជារឿងសំខាន់ដែលរាជរដ្ឋាភិបាលកម្ពុជា ចាប់ផ្ដើមផ្សព្វផ្សាយឯកសារនេះ ព្រោះវាជាជំហ៊ានមួយដ៏សំខាន់ ឆ្ពោះទៅរកការបំពេញកាតព្វកិច្ច របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបញ្ចូលសារធារណៈទៅក្នុងដំណើរការថវិកា និងដើម្បីបំពេញកាតព្វកិច្ចស្របច្បាប់របស់ខ្លួន ដូចមានចែងនៅក្នុងមាត្រា៨៤នៃច្បាប់ ដែលតម្រូវឲ្យរបាយការណ៍ហិរញ្ញវត្ថុ និងគណនេយ្យទាំងអស់ ផ្សព្វផ្សាយជាសារធារណៈ។ សំខាន់ជាងនេះទៀត ការផ្សព្វផ្សាយឯកសារនេះ និងឯកសារថវិកាផ្សេងៗទៀត តម្រូវឲ្យរាជរដ្ឋាភិបាលចំណាយថវិកាតិចតួច ឬមិនចំណាយថវិកាទាល់តែសោះ ព្រោះឯកសារនេះត្រូវបានធ្វើសម្រាប់ប្រើប្រាស់ផ្ទៃក្នុងរួចហើយ ។ ប្រសិនបើការផ្សព្វផ្សាយព័ត៌មាននេះធ្វើឡើងជាលក្ខណៈប្រព័ន្ធ ប្រទេសកម្ពុជាទំនងអាចកែលម្អលទ្ធផលរួមនៅក្នុង ការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាជុំបន្ទាប់។ | របាយការណ៍ពាក់កណ្ដាលឆ្នាំត្រូវតែផ្សព្វផ្សយជូនដល់សារធារណៈ **<u>មិនឲ្យលើសពីបីខែ</u>** បន្ទាប់ពីរយៈពេលធ្វើរបាយការណ៍បញ្ចប់។ |
| | **ឯកសារទី៦: របាយការណ៍ដំណាច់ឆ្នាំ** សង្ខេបអំពីស្ថានភាពនៃគណនីរបស់រដ្ឋាភិបាល ធៀបនឹងច្បាប់ថវិកា នៅចុងឆ្នាំសារពើពន្ធ ។ របាយការណ៍ដំណាច់ឆ្នាំអាចផ្ដល់ព័ត៌មានដល់សាធារណៈនូវការចំណាយរបស់រដ្ឋាភិបាលតាមវិស័យ និងតាមក្រសួង និងអាចត្រូវបានប្រើប្រាស់ដោយអ្នកធ្វើគោលនយោបាយ ដើម្បីដឹងពីថវិកានៅឆ្នាំខាងមុខ ។ នៅក្នុងប្រទេស | របាយការណ៍ដំណាច់ឆ្នាំត្រូវគេរំពឹងថានឹងត្រូវផ្សព្វផ្សាយជូនដល់សាធារណៈ**<u>មិនឲ្យលើសពីមួយឆ្នាំ</u>** បន្ទាប់ឆ្នាំសារពើពន្ធបញ្ចប់។ |

| | | |
|---|---|---|
| | កម្ពុជា ការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាធ្លាប់យកត្រូវបាន តារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ របស់រដ្ឋ និងព្រឹត្តិប័ត្រស្ថិតិប្រចាំខែជារបាយការណ៍ដំណាច់ឆ្នាំ ។ ប៉ុន្តែឯកសារទាំងនេះមិនត្រូវបានពិចារណា នៅក្នុងការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាបើកទូលាយ ឆ្នាំ២០១៥នោះទេ។ | |
| **ការត្រួតពិនិត្យ** | **ឯកសារទី៧: របាយការណ៍សវនកម្ម**គឺជាការវាយតម្លៃឯករាជ្យលើគណនីរបស់រដ្ឋាភិបាល (ការប្រមូលចំណូល និងចំណាយ) ដោយស្ថាប័នសវនកម្មជាន់ខ្ពស់។របាយការណ៍នេះរាយកាណ៍អំពីថាតើរដ្ឋាភិបាលបានបង្កើនចំណូល និងបានចំណាយថវិកាស្របតាមថវិកាដែលបានកំណត់ឬទេ និងថាតើគណនីរបស់រដ្ឋាភិបាលត្រឹមត្រូវ និងអាចជឿទុកចិត្តបានឬទេ ដើម្បីផ្តល់ជារូបភាពនៃស្ថានភាពសារពើពន្ធមួយដែលអាចជឿទុកចិត្តបាន។ នៅក្នុងប្រទេសកម្ពុជា របាយការណ៍ស្តីពីការអនុវត្តថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាលកម្ពុជា ត្រូវតែផ្ញើរជូនអង្គនីតិបញ្ញត្តិមុនពេលអនុម័តច្បាប់អនុវត្តថវិកាប្រចាំឆ្នាំ។ របាយការណ៍នេះត្រូវបានចាត់ទុកថាជាឯកសារសាធារណៈតាមមាត្រា ២៩ នៃច្បាប់ស្តីពីសវនកម្ម។ ប៉ុន្តែឯកសារនេះប្រហែលជាមិនបានត្រូវផ្សព្វផ្សាយ ជាសាធារណៈនោះទេ ឬប្រហែលត្រូវបានផ្សព្វផ្សាយ តែព័ត៌មានលម្អិតត្រូវបានលុបចោល ប្រសិនបើរបាយការណ៍នេះ មានព័ត៌មានដែលចាត់ទុកថាផ្ទុយទៅនឹងផលប្រយោជន៍ជាតិ ឬផលប្រយោជន៍ពាណិជ្ជកម្មរបស់ភ្នាក់ងារពាក់ព័ន្ធ របស់រាជរដ្ឋាភិបាល ដូចមានចែងក្នុងមាត្រា ៣៧ ៣៨ និង៣៩នៃច្បាប់ស្តីពីសវនកម្ម ។ នៅក្នុងប្រទេសកម្ពុជា របាយការណ៍ទាំងនេះត្រូវបានផ្សព្វផ្សាយ ឬ ផ្តល់ជូនតាមសំណើរ មិនតិចជាងពីរឆ្នាំ បន្ទាប់ឆ្នាំសារពើពន្ធបញ្ចប់ ។ នេះមិនបានបំពេញនូវស្តង់ដារទាបបំផុតនៃការអនុវត្តល្អរបស់អន្តរជាតិ ដែលចែងថា "របាយការណ៍សវនកម្មត្រូវតែរំពឹងថានឹងផ្សព្វផ្សាយដល់សាធារណៈ មិនឲ្យលើស ១៨ខែ បន្ទាប់ពីឆ្នាំសារពើពន្ធបញ្ចប់"។ សម្រាប់ប្រទេសកម្ពុជា វិធីសាស្រ្តការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាចាត់ទុក របាយការណ៍នេះបានរៀបចំឡើង តែមិនបានផ្សព្វផ្សាយ។ ការផ្សព្វផ្សាយនូវរបាយការណ៍សវនកម្ម ឲ្យបានទាន់ពេលវេលាធ្វើអោយតម្លាភាពថវិកាជារួមរបស់ប្រទេសកម្ពុជា មាន | របាយការណ៍សវនកម្មត្រូវតែផ្សព្វផ្សាយដល់សាធារណៈ **មិនឲ្យលើសពី១៨ខែ** បន្ទាប់ពីឆ្នាំសារពើពន្ធបញ្ចប់ ។ |

| | | |
|---|---|---|
| | ភាពប្រសើរឡើងនាពេលអនាគត ។ | |
| **គ្រប់ដំណាក់កាលថវិកា** | **ឯកសារទី៨: ឯកសារថវិកាសម្រាប់ប្រជាពលរដ្ឋ** គឺជាការបង្ហាញយ៉ាងសាមញ្ញ មិនមានភាពបច្ចេកទេស អំពីថវិការបស់រដ្ឋាភិបាល ដែលមានបំណងឲ្យសាធារណៈ រួមទាំងអ្នកដែលមិនយល់ដឹងអំពីហិរញ្ញវត្ថុសាធារណៈ យល់ដឹងកាន់តែច្បាស់នូវផែនការរដ្ឋាភិបាលក្នុងការបង្កើនចំណូល និងចំណាយថវិកាសាធារណៈ។ ចាប់តាំងពីឆ្នាំ២០០៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានផ្សព្វផ្សាយ "ថវិកាសង្ខេប" ដែលមានតួលេខចំណូល ចំណាយ និងសូចនាករម៉ាក្រូសេដ្ឋកិច្ចសរុបមួយចំនួន ប៉ុន្តែ ថវិកាសង្ខេបនេះ មិនត្រូវបានចាត់ទុកជាឯកសារថវិកាសម្រាប់ប្រជាពលរដ្ឋដ៏ល្អនោះទេ ផ្អែកតាមការអនុវត្តល្អរបស់អន្តរជាតិព្រោះ ឯកសារថវិការសង្ខេបមិនមានភាពទូលំទូលាយ ឬមិនបានផ្សព្វផ្សាយឲ្យទូលាយជាសាធារណៈនៅឡើយ ។ | ឯកសារថវិកាសម្រាប់ប្រជាពលរដ្ឋគួរត្រូវបានផ្សព្វផ្សាយតាមពេលវេលានៃឯកសារដែលបានយោង។ ឧទាហរណ៍ ប្រសិនបើជាឯកសារសំរួលចេញពី**ច្បាប់ថវិកា**គួរត្រូវបានផ្សព្វផ្សាយ មិនឲ្យលើសពី**បីខែ**បន្ទាប់ពីច្បាប់ថវិកាត្រូវបានអនុម័ត |

# ការចូលរួមជាសាធារណៈ

ភស្តុតាងបានបញ្ជាក់ថា តម្លាភាពតែមួយ មិនគ្រប់គ្រាន់សម្រាប់ការពង្រឹងអភិបាលកិច្ចបានទេ ប៉ុន្តែការចូលរួមរបស់សាធារណៈជនក្នុងដំណើរការថវិកា អាចធ្វើឲ្យមានផលវិជ្ជមានបានកាន់តែខ្ពស់ និងធ្វើឲ្យមានតម្លាភាពថវិកាកាន់តែល្អជាងមុន ។

ដើម្បីវាស់វែងទៅលើការចូលរួមរបស់សាធារណៈ ការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា បានធ្វើការប៉ាន់ប្រមាណទៅលើកម្រិត ដែលរដ្ឋាភិបាលផ្តល់ឱកាសឲ្យសាធារណៈចូលរួមក្នុងដំណើរការនៃថវិកា ។ អង្គនីតិប្រតិបត្តិ អង្គនីតិបញ្ញត្តិ និងស្ថាប័នសវនកម្មជាន់ខ្ពស់ គួរតែផ្តល់ឱកាសបែបនេះ ឲ្យសាធារណៈចូលរួមគ្រប់ដំណាក់កាលនៃដំណើរការថវិកា ។

ប្រទេសកម្ពុជាទទួលបានពិន្ទុ៨លើ១០០ពិន្ទុ ដែលបង្ហាញថា ការផ្តល់ឱកាសឲ្យសាធារណៈចូលរួម នៅក្នុងដំណើរការថវិកានៅមានភាពតិចតួច ។ ពិន្ទុនេះទាបជាងពិន្ទុមធ្យម(២៥ពិន្ទុ)សម្រាប់ប្រទេសដែលបានចូលរួមធ្វើការអង្កេតទាំង១០២។






# ប្រទេសកម្ពុជា

## ការត្រួតពិនិត្យថវិកា

ការអង្កេតនៃការផ្សព្វផ្សាយព័ត៌មានថវិកា ធ្វើការវាយតំលៃលើសមត្ថភាពនៃស្ថាប័ននិតិបញ្ញត្តិ និងស្ថាប័នសវនកម្មជាន់ខ្ពស់ក្នុងការពិនិត្យប្រកបដោយប្រសិទ្ធិភាពលើថវិកាជាតិ។ ស្ថាប័នទាំងពីរនេះដើរតួនាទីយ៉ាងសំខាន់ (ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ) ក្នុងការធ្វើផែនការថវិកា និងវាយតម្លៃលើការអនុវត្តរបស់ខ្លួន ។

### ការវាយតម្លៃដោយអង្គនីតិបញ្ញត្តិ

ការធ្វើផែនការ



ខ្សត់ខ្សោយ

ការអនុវត្ត



មានកំរិត

ស្ថាប័ននីតិបញ្ញត្តិ មានសមត្ថភាពខ្សោយក្នុងការត្រួតពិនិត្យថវិកាក្នុងដំណាក់ការរៀបចំផែនការថវិកា និងមានសមត្ថភាពនៅមានកំរិត ក្នុងការត្រួតពិនិត្យថវិកាក្នុងដំណាក់កាលនៃការអនុវត្តនៃវដ្តថវិកា ។ ស្ថាប័ននីតិបញ្ញត្តិ មិនមានការិយាល័យជំនាញលើការស្រាវជ្រាវស្តីពីថវិកា និងមិនមានការបង្កើតឲ្យមានការពិភាក្សាទៅលើការរៀបចំថវិកា ។

លើសពីនេះទៅទៀត ស្ថាប័ននីតិបញ្ញត្តិ ទាំងនៅក្នុងច្បាប់ និងការអនុវត្ត មិនបានធ្វើការពិភាក្សាជាមុនទៅលើការចំណាយថវិកាចៃដន្យផ្សេងៗ ដែលមិនបានកំណត់ក្នុងថវិកាដែលបានអនុម័ត។

### ការត្រួតពិនិត្យដោយស្ថាប័នសវនកម្មជាន់ខ្ពស់



មានកំរិត

សមត្ថភាពស្ថាប័នសវនកម្មជាន់ខ្ពស់ ក៏នៅមានកំរិតទាបក្នុងការត្រួតពិនិត្យថវិកា ។ តាមច្បាប់ ស្ថាប័នសវនកម្មជាន់ខ្ពស់មានសិទ្ធិពេញលេញក្នុងការអនុវត្តសវនកម្ម ពេលដែលគិតថាសាកសម ។ ជាងនេះទៅទៀត អ្នកគ្រប់គ្រងនៃស្ថាប័នសវនកម្មជាន់ខ្ពស់មិនអាចផ្លាស់ចេញ ដោយគ្មានការយល់ព្រមពីស្ថាប័ននីតិបញ្ញត្តិ រឺតុលាការ ដែលជំរុញអោយស្ថាប័នសវនកម្មជាន់ខ្ពស់នេះមានភាពឯករាជ្យ ។ ជាចុងក្រោយ ស្ថាប័នសវនកម្មជាន់ខ្ពស់ មិនត្រូវបានផ្តល់ធនធានគ្រប់គ្រាន់ដើម្បីបំពេញកាតួកិច្ច និងមានប្រព័ន្ធធានាគុណភាពនៅខ្សោយនៅឡើយ ។

## វិធីសាស្រ្ត

ការអង្កេតនៃការផ្សព្វផ្សាយព័ត៌មានថវិកា ប្រើប្រាស់លក្ខណៈវិនិច្ឆ័យទទួលស្គាល់ជាអន្តរជាតិ ដែលបង្កើតឡើងដោយអង្គការពហុភាគីរួមមាន មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) អង្គការសម្រាប់សហប្រតិបត្តិការ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD) និងអង្គការអន្តរជាតិនៃស្ថាប័នសវនកម្មជាន់ខ្ពស់ (INTOSAI) ។ ការអង្កេតនេះ ជាការស្រាវជ្រាវ ផ្អែកលើភាពជាក់ស្តែង ក្នុងការវាយតំម្លៃពីអ្វីដែលបានកើតឡើងក្នុងការអនុវត្តតាមរយៈការអង្កេតដែលបានរៀបចំជាស្រេច។ ដំណើរការស្រាវជ្រាវទាំងមូល ត្រូវចំណាយពេលប្រហែល១៨ខែ ដែលចាប់ផ្តើមពីខែមីនា ឆ្នាំ២០១៤ ដល់ខែកញ្ញា ឆ្នាំ ២០១៥ ដែលបានចូលរួមពីអ្នកជំនាញប្រហែល ៣០០នាក់ មកពី ១០២ប្រទេស ។ ការអង្កេតនេះ ត្រូវបានកែសម្រួលបន្ថិច

អង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា

# ប្រទេសកម្ពុជា

បន្ទូច ពីការអង្កេតឆ្នាំ២០១២ ដើម្បីឆ្លុះបញ្ចាំងពីការអភិវឌ្ឍថ្មីៗ ដែលទទួលយកការអនុវត្តល្អ និងធ្វើការពង្រឹងនៃសំនួរនិមួយៗ ។ ការពិភាក្សាលំអិតទៅលើការផ្លាស់ប្តូរទាំងនេះ អាចស្វែងរក នៅក្នុងកំណត់ត្រាបច្ចេកទេសលើការប្រៀបធៀបសន្ទស្សន៍ នៃការផ្សព្វផ្សាយព័ត៌មានថវិកាពីមួយឆ្នាំទៅមួយឆ្នាំនៅក្នុងអាស័យដ្ឋានខាងក្រោម ។

ការឆ្លើយតបសំនួរនៃការអង្កេតនេះ ត្រូវបានគាំទ្រដោយអំណះអំណាងច្បាស់លាស់ ដូចជា ឯកសារយោងជាសាធារណៈ សេចក្តីថ្លែងការជាផ្លូវការរបស់រាជរដ្ឋាភិបាល ឬអនុសាសន៍ដែលបានមកពីកិច្ចសម្ភាសន៍មួយទល់មួយ ជាមួយមន្ត្រីរដ្ឋាភិបាល ឬភាគីដែលបានដឹងឮដទៃទៀត ។

ការអង្កេតនៃការផ្សព្វផ្សាយព័ត៌មានថវិកា ត្រូវបានរៀបចំឡើងពីការបំពេញកម្រងសំនួរសម្រាប់ប្រទេសនីមួយៗ ដោយអ្នកជំនាញថវិកាឯករាជ្យ ដែលមិនជាប់ទាក់ទងនឹងរដ្ឋាភិបាលរបស់ប្រទេសនីមួយៗ ។ បន្ទាប់មក កំរងសំនួរបស់ប្រទេសនីមួយៗ ត្រូវបានត្រួតពិនិត្យដោយឡែកៗពីគ្នា ដោយអ្នកជំនាញអនាមិក ដែលមិនជាប់ទាក់ទងទៅនឹងរដ្ឋាភិបាល ។ លើសពីនេះទៅទៀត ភាពជាដៃគូថវិកាអន្តរជាតិ (IBP) អញ្ជើញរដ្ឋាភិបាលប្រទេសនីមួយៗ ដើម្បីផ្តល់អនុសាសន៍ទៅលើសេចក្តីព្រៀងលទ្ធផលនៃការអង្កេតនេះ និងការធ្វើការពិនិត្យលើអនុសាសន៍ទាំងនេះ មុនពេលចេញលទ្ធផលចុងក្រោយ។

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក៏បានផ្តល់អនុសាសន៍ទៅលើសេចក្តីព្រៀងលទ្ធផល នៃកម្រងសំនួរការអង្កេតនៃការផ្សព្វផ្សាយព័ត៌មានថវិកាដែរ។




# អនុសាសន៍

## ការពង្រឹងតម្លាភាពថវិកា

ដើម្បីពង្រឹងតម្លាភាពថវិកា រាជរដ្ឋាភិបាលកម្ពុជាគួរតែផ្តល់អាទិភាពទៅលើសកម្មភាពដូចខាងក្រោម ៖

- ផ្សព្វផ្សាយសំណើរថវិការបស់ស្ថាប័ននីតិប្រតិបត្តិតាមពេលវេលាដែលបានកំណត់គឺមុនពេលផ្ញើរជូនទៅរដ្ឋសភា
- ផ្សព្វផ្សាយរបាយការណ៍ពាក់កណ្តាលឆ្នាំ ក្នុងរយ:ពេលបីខែនៃពាក់កណ្តាលឆ្នាំ
- ផ្សព្វផ្សាយរបាយការណ៍ក្នុងឆ្នាំ និងឯកសារថវិកាសម្រាប់ប្រជាពលរដ្ឋ ឲ្យទាន់ពេលវេលា

# ប្រទេសកម្ពុជា

### ការពង្រឹងការចូលរួមសាធារណៈជនលើដំណើរការថវិកា

ដើម្បីពង្រឹងការចូលរួមលើដំណើរការថវិកា រាជរដ្ឋាភិបាលកម្ពុជាគួរតែផ្តល់អាទិភាពទៅលើសកម្មភាពដូចខាងក្រោម ៖

- បង្កើតយន្តការដែលគួរឲ្យជឿជាក់បាន និងមានប្រសិទ្ធភាព (ឧទាហរណ៍: ការចូលរួមស្តាប់ជាសាធារណៈ ការស្ទាបស្ទង់មតិ ការពិភាក្សាជាក្រុម) ក្នុងការទទួលបានទស្សនៈសាធារណៈ អំពីបញ្ហាថវិកា។
- ផ្តល់ដល់សាធារណៈជននូវឱកាស ក្នុងការផ្តល់សក្ខីកម្មនៅក្នុងការពិភាក្សា របស់ស្ថាប័ននីតិបញ្ញត្តិទៅលើការសម្រេចថវិកាតាមក្រសួង នាយកដ្ឋាន និងផ្នែកផ្សេងៗ ។
- បង្កើតយន្តការផ្លូវការ សម្រាប់សាធារណៈជនចូលរួមជួយស្ថាប័នសវនកម្មជាន់ខ្ពស់ ក្នុងការបង្កើតកម្មវិធីសវនកម្ម និងចូលរួមស៊ើបអង្កេតលើសវនកម្ម ។

### ការពង្រឹងលើការត្រួតពិនិត្យ

ដើម្បីពង្រឹងសមត្ថភាពត្រួតពិនិត្យទៅលើថវិកា ប្រទេសកម្ពុជាគួរតែផ្តល់អាទិភាពទៅលើសកម្មភាពដូចខាងក្រោម ៖

- បង្កើតការិយាល័យជំនាញស្រាវជ្រាវ សម្រាប់ស្ថាប័ននីតិបញ្ញត្តិ
- ទាំងក្នុងច្បាប់ និងការអនុវត្ត ត្រូវធានាថាស្ថាប័ននីតិបញ្ញត្តិ ត្រូវបានធ្វើការពិគ្រោះយោបល់មុនពេលថវិកាចំណាយ ឬថវិកាដែលមិនបានស្នើនៅក្នុងច្បាប់ថវិកា ។
- ធានាថាស្ថាប័នសវនកម្មជាន់ខ្ពស់ មានថវិកាគ្រប់គ្រាន់ ក្នុងការបំពេញភារកិច្ច ដូចបានកំណត់ដោយស្ថាប័នឯករាជ្យ (ឧទាហរណ៍: អង្គនីតិបញ្ញត្តិ ឬ តុលាការ) ។

## តើហេតុអ្វីបានជារាជរដ្ឋាភិបាលកម្ពុជាគួរតែផ្សព្វផ្សាយឯកសារថវិកាទាំងនេះ?

រាជរដ្ឋាភិបាលកម្ពុជា ដែលបានផ្សព្វផ្សាយឯកសារថវិកាសំខាន់ៗទាំង៨ បានទាន់ពេលវេលា នឹងផ្តល់សារដ៏សំខាន់ដល់មជ្ឈដ្ឋានអន្តរជាតិ និងមជ្ឈដ្ឋានជាតិទៅ ដូចដូចតទៅ៖

### កម្រិតអន្តរជាតិ

- បង្ហាញអំពីការតាំងចិត្តរបស់រដ្ឋាភិបាល ដើម្បីលុបបំបាត់អំពើពុករលួយ ក៏ដូចជា បង្ហាញពីភាពជោគជ័យនៃការពង្រឹងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដែលត្រូវបានអនុម័ត និងប្រកាសឲ្យប្រើប្រាស់នៅក្នុងឆ្នាំ ២០១០។
- ការធ្វើឲ្យប្រសើរឡើង នូវមុខមាត់របស់ប្រទេសកម្ពុជា និងការធ្វើឲ្យពិន្ទុនៃសន្ទស្សន៍ការផ្សព្វផ្សាយព័ត៌មានថវិកាបានខ្ពស់ នឹងអាចជួយទាក់ទាញឲ្យមានការវិនិយោគទុនពីបរទេស ឬការគ្រប់គ្រងជំនួយ ពីបរទេស ។ ទាំងនេះជួយអោយប្រទេសកម្ពុជាសម្រេចបាននូវរបៀបវារៈអភិវឌ្ឍន៍របស់ខ្លួន។

### កម្រិតជាតិ

- រដ្ឋាភិបាលអាចប្រើប្រាស់ទិន្នន័យ ដែលមានលក្ខណៈទូលំទូលាយ និងទាន់ពេលវេលា ដើម្បីជួយការសម្រេចចិត្តអំពីថវិកាបានកាន់តែត្រឹមត្រូវ។
- បង្កើនការទុកចិត្តពីប្រជាជនក្នុងប្រទេស ក៏ដូចជាប្រជាជនកម្ពុជាទាំងមូល ព្រោះពួកគេបានដឹងពីលទ្ធផលសម្រេចបាន របស់រដ្ឋាភិបាលក្នុងការងារ

រយៈពេលថ្មីនេះ ទៅលើការវិវឌ្ឍន៍នៃការអនុវត្តន៍ការកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងធ្វើឲ្យមានការចូលរួមសកម្មថែមទៀត នៅក្នុងដំណើរការថវិកា ដើម្បីដោះស្រាយភាពខ្វះខាតដែលកើតមាន

- វាក៏ជាសារដើម្បីបង្ហាញថា រដ្ឋាភិបាលមានភាពទទួលខុសត្រូវ ចំពោះការប្រើប្រាស់ថវិកាសាធារណៈដែលឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។
- ប្រជាពលរដ្ឋអាចមើលឃើញ អំពីប្រសិទ្ធភាព និងប្រសិទ្ធផលនៃប្រព័ន្ធថវិកា របស់រដ្ឋាភិបាលនៅក្នុងការរួមវិភាគទាននៅដល់ការកាត់បន្ថយភាពក្រីក្រ និងការធ្វើឲ្យប្រសើរឡើង នៃសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។
- សាធារណៈជនទទួលស្គាល់អំពីឯករាជ្យភាព របស់អាជ្ញាធរសវនកម្មជាតិ ដោយគ្រាន់តែធ្វើឲ្យប្រសើរឡើង តាមរយៈការផ្សព្វផ្សាយឲ្យទាន់ពេលវេលា នៃរបាយការណ៍សវនកម្ម ដែលអាចឲ្យរដ្ឋសភាទាមទារឲ្យរដ្ឋាភិបាលទទួលខុសត្រូវ។

## សំរាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖

INTERNATIONAL BUDGET PARTNERSHIP
Open Budgets. Transform Lives.

ភាពជាដៃគូថវិកាអន្តរជាតិ(IBP) គឺជាអង្គការអន្តរជាតិក្រៅរដ្ឋាភិបាលដែលសហការ ជាមួយអង្គការសង្គមស៊ីវិលជាង ១០០ប្រទេសនៅទូទាំងពិភពលោក ដើម្បីធានាថា ថវិកា រដ្ឋាភិបាលមានភាពទទួលខុសត្រូវខ្ពស់នឹងឆ្លើយតបនឹងតម្រូវការ របស់ប្រជាជនក្រីក្រ និងប្រជាជនដែលមានកម្រិតប្រាក់ចំណូលទាបនៅក្នុងសង្គម និងតាមលំដាប់លំដោយ ដើម្បីបង្កើតឲ្យមានប្រព័ន្ធថវិកា មានតម្លាភាព និងការទទួល ខុសត្រូវកាន់តែច្រើនទៅដល់សាធារណៈ។ ភាពជាដៃគូថវិកាអន្តរជាតិមាន ការិយាល័យនៅទីក្រុងវ៉ាស៊ីនតោនឌីស៊ី ខែបថោន សាវ អាហ្វ្រិកខា មិមបៃ ឥណ្ឌាណៃរ៉ូប៊ី និង កេនយ៉ា និង បុគ្គលិកទាំងអស់ស្ថិតនៅក្នុងប្រទេស អេហ៊ីបចក្រភព អង់គ្លេស និង ប្រេស៊ីល។

**អាស័យដ្ឋាន:** 820 First Street, NE Suite 510 Washington, DC 20002 U.S.

Tel: +1 202 408 1080 | Fax: +1 202 408 8173

**អ៊ីម៉ែល:** firstinitiallastname@internationalbudget.org

**គេហទំព័រ:** www.internationalbudget.org និង/ ឬ

www.openbudgetindex.org

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា
The NGO Forum on Cambodia

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពី កម្ពុជា(NGOF) គឺជាអង្គការសមាជិកភាពសម្រាប់អង្គការក្នុងស្រុក និងអង្គការ មិនមែនរដ្ឋាភិបាលអន្តរជាតិ ដែលបានកសាងកិច្ចសហការ និងសមត្ថភាពរបស់អង្គការ គាំទ្របណ្តាញអង្គការ និង អង្គការសង្គម ស៊ីវិលផ្សេងៗ ដើម្បីភ្ជាប់ឲ្យមានទំនាក់ទំនងក្នុងកិច្ចពិភាក្សានយោបាយ ការជជែកពិភាក្សាគ្នា និង ឥស្ស៊ូមតិ។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ធ្វើការដើម្បីធានាឲ្យមានសិទ្ធិគ្រប់គ្រាន់ ទៅដល់ប្រជាជនក្រីក្រ និងប្រជាជានដែលងាយរងគ្រោះ ឲ្យមានការទទួល ស្គាល់ និងគាំទ្រដោយគោលនយោបាយ និងការអនុវត្តន៍ របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងដៃគូរ អភិវឌ្ឍន៍ និងសហគមឲ្យបានទូលំទូលាយជាងមុន។

**អាសយដ្ឋាន:** ផ្ទះលេខ៩-១១ផ្លូវ៤៧៦ សង្កាត់ទួលទំពូង១ ប្រអប់សំបុត្រលេខ២២៩៥ ភ្នំពេញ។

**អ៊ីម៉ែល:** ngoforum@ngoforum.org.kh

**គេហទំព័រ:** www.ngoforum.org.kh និង/ ឬ

www.cambodianbudget.org


88
87
86
84
81
77
76
75
75
75
74
73
71
69
68
66
66
65
65
65
64
64
64
62
59
59
58
58
57
57
56
55
55
54
54
53
53
52
51
51
51
51
51
50
49
48
47
47
46
46
46
46
46
46
46
46
45
44
44
43
43
43
43
43
42
42
42
41
39
39
39
38
38
38
38
36
35
35
34
34
29
26
25
24
24
19
18
17
17
16
15
14
10
8
8
4
4
3
2
2
គ្រប់គ្រាន់
ទូលំទូលាយ
ទំហំធំ
មានដែនកំណត់
មិនគ្រប់គ្រាន់
ខ្វះខាត ឬ គ្មាន

# OPEN BUDGET SURVEY 2015 CAMBODIA

| TRANSPARENCY (OPEN BUDGET INDEX) | PUBLIC PARTICIPATION | BUDGET OVERSIGHT | |
|---|---|---|---|
| **8** OUT OF 100 | **8** OUT OF 100 | **43** OUT OF 100 | **58** OUT OF 100 |
| The Government of Cambodia provides the public with **scant** budget information. | The Government of Cambodia is **weak** in providing the public with opportunities to engage in the budget process. | **BY LEGISLATURE** Budget oversight by the legislature in Cambodia is **limited**. | **BY AUDIT** Budget oversight by the supreme audit institution in Cambodia is **limited**. |

## WHAT IS THE OPEN BUDGET SURVEY (OBS)?

The Open Budget Survey is a unique research and analysis initiative that uses documented evidence and objective criteria to evaluate three pillars of budget transparency and accountability. It considers:

- The extent to which national or central governments provide the public with timely and comprehensive access to the eight key budget documents required by international good practice;
- The degree to which opportunities for public participation in the budget process are present; and
- The ability of legislatures and supreme audit institutions to provide effective oversight of government budgets

It is an independent, comparable and regularly measure of budget transparency and accountability produced by independent civil society budget experts not affiliated with any national government. The foundation of the Survey is a 140 question Open Budget Survey Questionnaire. The survey is conducted biennially (every two years) to review the progress made by the countries. 2015 is the fifth OBS and the survey was conducted of 102 countries. This is the fourth OBS for Cambodia. The 2015 results reflect the research conducted by independent civil society researchers based on data collected in 2014.

## TRANSPARENCY (OPEN BUDGET INDEX)

Drawing on internationally accepted criteria developed by multilateral organizations, the Open Budget Survey uses 109 indicators to measure budget transparency. These indicators are used to assess whether the central government makes eight key budget documents available to the public in a timely manner and whether the data contained in these documents are comprehensive and useful.

Each country is given a score out of 100 which determines its ranking on the Open Budget Index – the world's only independent and comparative measure of budget transparency.

# OPEN BUDGET SURVEY 2015 CAMBODIA

### Usefulness of Budget Information Throughout the Budget Cycle




Note: The following categories are used to report the usefulness of each document:
**Not produced, Published Late, Internal Use, Scant, Minimal, Limited, Substantial,** or **Extensive.**

### The Availability of Budget Documents Over Time

| Document | 2008 | 2010 | 2012 | 2015 |
|---|---|---|---|---|
| Pre-Budget Statement | ● (yellow) | ● (green) | ● (green) | ● (green) |
| Executive's Budget Proposal | ● (yellow) | ● (yellow) | ● (yellow) | ● (yellow) |
| Enacted Budget | ● (green) | ● (green) | ● (green) | ● (green) |
| Citizens Budget | ● (red) | ● (red) | ● (red) | ● (red) |
| In-Year Reports | ● (green) | ● (green) | ● (green) | ● (red) |
| Mid-Year Review | ● (yellow) | ● (yellow) | ● (yellow) | ● (yellow) |
| Year-End Report | ● (green) | ● (green) | ● (green) | ● (red) |
| Audit Report | ● (yellow) | ● (yellow) | ● (yellow) | ● (red) |

● Not produced/published late ● Produced for internal use ● Published

Cambodia's score of 8 on the 2015 Open Budget Index is lower than its score in 2012.

Since 2012, the Government of Cambodia has decreased the availability of budget information by:

- Failing to publish the In-Year Reports in a timely manner.
- Moreover, the Government of Cambodia has failed to make progress in the following ways:
- Not making the Executive's Budget Proposal available to the public.
- Not making the Mid-Year Review available to the public.
- Producing a Citizens Budget but failing to make it available to the public in a timely manner.

### Regional Comparison




Cambodia's score of 8 out of 100 is substantially lower than the global average score of 45.

### Change in Transparency Over Time



OPEN BUDGET SURVEY 2015 CAMBODIA

**Detail Information of Eight Key Documents**

| Stage in Budget Cycle | Budget Document | Time to release based on the International Good Practice |
|---|---|---|
| **Formulation** | **Document 1: The Pre-Budget Statement** provides information (previous and current year macroeconomic performance and projection of the coming budget or fiscal year) that links government policies and budgets. Cambodia has published the Royal Government Circular on Guidelines for Preparation of the Draft Budget Law in the Government Official Gazette since 2009, which is publically accessible at a minimal cost. | **The Pre-Budget Statement** must be published **one month before the draft budget law** is submitted to the legislature for consideration. |
| | **Document 2: The Executive's Budget Proposal** is document that the MEF submit to the Legislature for approval. It is the government's most important policy instrument as it presents how the government plans to raise revenues through taxes and other sources, and spend those monies to support its priorities including the budget allocation to different sectors, thereby transforming policy goals into action. The Royal Government of Cambodia produces this document for internal use, but does not publish the document for public access as required by international good practice. It is noted that in November 2010, the Draft Budget Law 2011 was released by the MEF and the National Assembly (NA) to the NGO Forum on Cambodia upon its request. However, since 2011, the MEF has not released the document. | The executive budget proposal must be released to the public **while the legislature is still considering** it or before the legislature approves (enacts) the budget. |
| **Approval** | **Document 3: The Enacted Budget** is the budget that has been approved by the legislature. It becomes the country's law authorizing the executive to raise revenues, make expenditures and incur debts. The document provides baseline information for all budget analyses conducted during the budget year. In general, the Enacted Budget should provide the public with the necessary data it needs to assess the government's stated policy priorities and hold the government accountable. Cambodia publishes its annual Enacted Budget or Law on Finance in the Official Gazette. However, this document does not contain program-level details for expenditure. | The enacted budget must be released to the public **no later than three months** after it is approved by legislature. |
| **Execution** | **Document 4: In-Year Reports** provide a snapshot of the budget progress of implementing the budget | In Year report must be released to the public **no** |

| | | |
|---|---|---|
| | including the information on actual revenues collected, actual expenditure made and debt incurred at different interval in the fiscal year. Cambodia's In-Year Reports consists of monthly bulletin of statistic and TOFEs (Table of Public Financial Operation) on the progress of revenue and expenditure in each month and year to date. However, these reports lack important details such as breakdowns of expenditures by line ministries, detailed explanations of the difference between actual and planned revenues and expenditures, and regular updates or posting on the MEF's website/other public domain. Importantly, the monthly bulletin of statistic has not been published since 2014 due to the MEF's reconstruction of its website. | **later than three months** after the reporting period ends. |
| | **Document 5: The Mid-Year Review** provides a comprehensive update on the implementation of budget at the mid-point of a budget year. Information in this report allows the government's fiscal performance to be assessed against the plan laid out in the original budget. It allows the government, legislature, and public to identify whether or not adjustments related to revenues, expenditures, or borrowing should be made during the last six months of the year. In Cambodia, the MEF produces the Mid-Year Review for internal use only. It is important that the RGC starts publishing this document as it is an important step towards the RGC fulfilling its obligation to engage the public in the budget process and to fulfill its legal duty as stipulated in Article 84 of the law, which requires all financial and accounting reports to be publicly disclosed. Significantly, the release of this document, as well as other budget documents, requires minimal or no financial cost to the RGC because it is already produced for internal use. If this release of information occurs in a systematic manner, Cambodia is likely to improve its overall results in the next round of OBS. | Mid Year Review report must be released to the public **no later than three months** after the reporting period ends. |
| | **Document 6: The Year-End Report** outlines the situation of the government account compare to the enacted budget at the end of fiscal year. Year-End Reports can inform the public of the government's spending by sectors and ministry and can be used by policymakers to inform budget in upcoming years. In Cambodia, OBS used to consider the TOFE and Monthly bulletin statistic as the Year-End Report. However, these documents were not considered in the OBS 2015 round. | The yearend report is expected to be released to the public **no later than one year** after the end of fiscal year to which it corresponds. |

| | | |
|---|---|---|
| **Oversight** | **Document 7: The Audit Report** is an independent evaluation of the government's accounts (collection of revenues and expenditures) by the country's Supreme Audit Institution (SAI). It reports whether the government has raised revenues and spent monies in line with the authorized budget, and whether the government's accounts are accurate and can be relied upon to provide a reliable picture of the fiscal situation. In Cambodia, audit reports on the RGC's annual budget implementation must be submitted to the legislature prior to the adoption of the annual budget execution law. The report is considered a public document by Article 29 of the Law on Audit. However, it may not be publically disclosed, or it may be disclosed with detailed information omitted, if it contains information considered to be contrary to the national or commercial interest of relevant agencies of the RGC as provided by Article 37, 38 and 39 of the law. In Cambodia, these reports have been released or made available upon request later than two years after the end of the fiscal year. This does not meet the minimum standard of international good practice, which provides that "audit report expected to be available to the public no later than 18 months after end of the fiscal year." For Cambodia, the OBS methodology considered that the reports have been produced, but not published. A timely release of audit reports should improve Cambodia's overall budget transparency score in the future. | Audit report must be available to the public **no later than 18 months** after end of the fiscal year. |
| **All stages** | **Document 8: A Citizens Budget** is a nontechnical presentation (simplified version) of a government's budget that is intended to enable the public — including those who are not familiar with public finance — to better understand the government plans for raising revenues and spending public funds. Since 2014, the MEF has published a "budget in brief", which contained some aggregate figures of revenues, expenditure and macroeconomic indicators. However, this budget in brief is not considered a Citizens Budget based on international best practice because it was not comprehensive or widely disseminate to the public. | Follow the timeline of document it refers to. E.g. if it is simplifies the **Enacted Budget**, it must be released **no later than three months** after the budget is approved. |

# OPEN BUDGET SURVEY 2015 > CAMBODIA

## PUBLIC PARTICIPATION

Evidence suggests that transparency alone is insufficient for improving governance, and that public participation in budgeting can maximize the positive outcomes associated with greater budget transparency. To measure public participation, the Open Budget Survey assesses the degree to which the government provides opportunities for the public to engage in budget processes. Such opportunities should be provided throughout the budget cycle by the executive, the legislature, and the supreme audit institution.

Cambodia's score of 8 out of 100 indicates that the provision of opportunities for the public to engage in the budget process is weak. This is lower than the global average score of 25.

**Regional Comparison**




**Elements of Public Participation**




## OVERSIGHT BUDGET

The Open Budget Survey examines the extent to which legislatures and supreme audit institutions are able to provide effective oversight of the budget. These institutions play a critical role – often enshrined in national constitutions – in planning budgets and overseeing their implementation.

**Oversight by the Legislature**




The legislature provides weak oversight during the planning stage of the budget cycle and limited oversight during the implementation stage of the budget cycle. The legislature does not have a specialized budget research office, and a pre-budget debate by the legislature does not take place.

Moreover, in both law and practice, the legislature is not consulted prior to spending contingency funds that were not identified in the Enacted Budget.

**Oversight by the Supreme Audit Institution**




The supreme audit institution provides limited budget oversight. Under the law, it has full discretion to undertake audits as it sees fit. Moreover, the head of the supreme audit institution cannot be removed without legislative or judicial approval, which bolsters

its independence. Finally, the supreme audit institution is provided with insufficient resources to fulfill its mandate and has a weak quality assurance system in place.

## METHODOLOGY

The Open Budget Survey uses internationally accepted criteria developed by multilateral organizations such as the International Monetary Fund (IMF), the Organisation for Economic Co-operation and Development (OECD), and the International Organisation of Supreme Audit Institutions (INTOSAI). It is a fact-based research instrument that assesses what occurs in practice through readily observable phenomena. The entire research process took approximately 18 months between March 2014 and September 2015 and involved about 300 experts in 102 countries. The Survey was revised somewhat from the 2012 version to reflect emerging developments in accepted good practice and to strengthen individual questions. A full discussion of these changes can be found in a technical note on the comparability of the Open Budget Index over time (see address below).

Survey responses are typically supported by citations and comments. This may include a reference to a public document, an official statement by the government or comments from a face-to-face interview with a government official or other knowledgeable party.

The Survey is compiled from a questionnaire completed for each country by independent budget experts who are not associated with the national government. Each country's questionnaire is then independently reviewed by an anonymous expert who also has no association to government. In addition, IBP invites national governments to comment on the draft results from the Survey and considers these comments before finalizing the Survey results.

The Government of Cambodia provided comments on the draft Open Budget Questionnaire results.

Research to complete this country's Open Budget Survey was undertaken The NGO Forum on Cambodia.



OPEN BUDGET SURVEY 2015 > CAMBODIA

## RECOMMENDATIONS

**Improving Transparency**

The Royal Government of Cambodia should prioritize the following actions to improve budget transparency:

- Publish an Executive's Budget Proposal within the relevant timeframe (that is when the budget is sent to parliament)
- Publish a Mid-Year Review within three months of the middle of the fiscal year
- Publish in a timely manner a Citizens Budget and In-Year Reports.

**Improving Participation**

The Royal Government of Cambodia should prioritize the following actions to improve budget participation:

- Establish credible and effective mechanisms (i.e., public hearings, surveys, focus groups) for capturing a range of public perspectives on budget matters.
- Hold legislative hearings on the budgets of specific ministries, departments, and agencies at which testimony from the public is heard.
- Establish formal mechanisms for the public to assist the supreme audit institution to formulate its audit program and participate in audit investigations.

**Improving Oversight**

The Royal Government of Cambodia should prioritize the following actions to strengthen budget oversight:

- Establish a specialized budget research office for the legislature.
- In law and practice, ensure the legislature is consulted prior to the spending of contingency funds that were not identified in the Enacted Budget.
- Ensure the supreme audit institution has adequate funding to perform its duties, as determined by an independent body (e.g., the legislature or judiciary).

## WHY SHOULD THE ROYAL GOVERNMENT OF CAMBODIA PUBLISH THESE BUDGET DOCUMENTS?

The Royal Government of Cambodia publishing these eight key budget documents in a timely manner would provide a strong message to international and local communities as the following:

**International level**

1- Shows the government's commitment to combat the corruption as well as the successful enforcement of the anti-corruption law adopted and promulgated in 2010.

2- Improved image of the country and a higher OBI score will help to attract more foreign direct investment or managing development aid. This would assist with meeting the Cambodian development agenda.

**Local level**

1- The government can use more comprehensive and timely data to make better budget decisions.

2- Increase trust from the local communities as Cambodian citizens are (fully) aware of the government's achievement in its current work on progression of PFMRP implementation and may participate more

OPEN BUDGET SURVEY 2015 CAMBODIA

actively in the budget process toward addressing the gap

3- Show the government are accountable in using the public fund based on the citizens needs

4- Citizens are able to see the effectiveness and efficiency of the government's budget system in contributing to the poverty reduction and improving the economy of the country.

5- Public view on the independence of the NAA from the government could be improved through timely publication of the audit report which allows for the NA to hold the government accountable;

**FOR FURTHER INFORMATION, PLEASE CONTACT ADDRESS BELOW:**

| | |
|---|---|
| IBP INTERNATIONAL BUDGET PARTNERSHIP Open Budgets. Transform Lives.<br>The International Budget Partnership is an international nongovernmental organization that collaborates with civil society organizations in over 100 countries around the world to ensure that government budgets are more responsive to the needs of poor and low-income people in society and, accordingly, to make budget systems more transparent and accountable to the public. IBP has offices in Washington, D.C.; Cape Town, South Africa; Mumbai, India; and Nairobi, Kenya; and staff based in Egypt, the U.K, and Brazil.<br>***Address:*** 820 First Street, NE Suite 510<br>Washington, DC 20002 U.S.<br>Tel: +1 202 408 1080 \| Fax: +1 202 408 8173<br>Email: firstinitiallastname@internationalbudget.org<br>Website: www.internationalbudget.org and www.openbudgetindex.org | The NGO Forum on Cambodia<br>The NGO Forum on Cambodia is a membership organization for local and international non-governmental organization that build NGO cooperation and capacity, supporting NGO network and other civil society organization to engage in policy dialogue, debate and advocacy. It works to ensure the rights of the poor and vulnerable are recognized and supported by the policies and practices of Cambodia's government and development partners and the wider community.<br>**Address:** # 9-11, St.476, Toul Tompong 1, P.O.Box 2295, Phnom Penh, Cambodia<br>Email: ngoforum@ngoforum.org.kh<br>Website: www.ngoforum.org.kh or www.cambodianbudget.org |